# ច្បាប់ស្តីពីការអនុម័តយល់ព្រម ឲ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីជីវចម្រុះ (០១២០៦០៦)

# ព្រះរាជក្រម

នស/រកម/០៦០៦/០១២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញា ស្តីពីជីវចម្រុះ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះបានទាន់ពេលវេលាស្របតាម មាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញា ស្តីពីជីវចម្រុះ

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាស្តីពីជីវចម្រុះ ដែលធ្វើនៅទីក្រុងរីយ៉ូដឺហ្សាណេរ៉ូ ប្រទេសប្រេស៊ីល នាថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.០២៦ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ហត្ថលេខា

ម៉ុក ម៉ារ៉េត

លេខ ៤២៥៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ឌិនកេង

# អនុសញ្ញាអន្តរជាតិស្តីពី

# ជីវៈចំរុះ

ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ១៩៩២

## Convention on

# BIOLOGICAL DIVERSITY

5 June 1992

ប្រែសំរួលដោយ : គំរោងយុទ្ធសាស្ត្រ និង ផែនការសកម្មភាពជាតិ
ស្តីពីជីវៈចំរុះ ក្រសួងបរិស្ថាន
ខែ តុលា ឆ្នាំ ២០០២

# អនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះ
## ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩២

## បុព្វកថា

ភាគីចុះកិច្ចសន្យា :

*ដោយយល់ដឹងពី*តំលៃធម្មជាតិនៃជីវៈចំរុះ និងតំលៃសោភ័ណភាព កែកំសាន្ត វប្បធម៌ អប់រំ វិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម សេនេទិច និង អេកូឡូស៊ីនៃជីវៈចំរុះ និងសមាសភាពរបស់វា ។

*ដោយយល់ដឹងផងដែរពី* សារៈសំខាន់នៃជីវៈចំរុះសំរាប់ការវិវត្តន៍ និងរក្សាដល់ប្រព័ន្ធនិរន្តរភាព ជីវិតនៃជីវភាព ។

ដោយអះអាងថា ការអភិរក្សជីវៈចំរុះគឺជាក្តីព្រួយបារម្ភរបស់មនុស្សជាតិ ។

ដោយអះអាងជាថ្មីផងដែរថា រដ្ឋត្រូវទទួលខុសត្រូវសំរាប់ការអភិរក្សជីវៈចំរុះរបស់ខ្លួន និងសំរាប់ការប្រើប្រាស់ធនធានជីវៈចំរុះនោះក្នុងមធ្យោបាយនិរន្តរភាព ។

ដោយព្រួយបារម្ភថាជីវៈចំរុះត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសកម្មភាពមនុស្ស ។

យល់ដឹងពីការខ្វះខាត ព័ត៌មានទូទៅ និងចំណេះដឹងទាក់ទងទឹងជីវៈចំរុះ និងតំរូវការបន្ទាន់ដើម្បីអភិវឌ្ឍន៍សមត្ថភាព ស្ថាប័ន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រ ដើម្បីផ្តល់ការយល់ដឹងជាមូលដ្ឋានក្នុងការធ្វើផែនការ និងអនុវត្តវិធានការសមស្រប ។

ដោយកត់សំគាល់ឃើញថា វាមានសារៈសំខាន់ជាអាយុជីវិតដើម្បីរំពឹងទុកជាមុន ការពារ និងទប់ស្កាត់មូលហេតុធ្វើអោយធ្លាក់ចុះ ឬប្រភពដែល ធ្វើអោយបាត់បង់ជីវៈចំរុះ ។

ដោយកត់សំគាល់ជារួមថា នៅទីកន្លែងណាដែលមានការគំរាមកំហែងធ្វើអោយធ្លាក់ចុះ ឬ ការបាត់បង់ជីវៈចំរុះច្រើនមិនគួរប្រើប្រាស់ការខ្វះខាតនូវភាពច្បាស់លាស់ខាងវិទ្យាសាស្ត្រជាហេតុផលនៃវិធានការពន្យារដើម្បីជៀសវាង ឬកាត់បន្ថយជាអប្បបរមានូវការគំរាមកំហែងនោះទេ ។

ដោយកត់សំគាល់បន្ថែមថាតំរូវការមូលដ្ឋានសំរាប់អភិរក្សជីវៈចំរុះ ជាការអភិរក្សក្នុងតំបន់នៃប្រព័ន្ធអេកូឡូស៊ី និងដែនជំរកធម្មជាតិ និងជាការថែរក្សា ស្តារឡើងវិញនៃចំនួនប្រភេទដែលនៅមានជីវិតក្នុងបរិស្ថានធម្មជាតិរបស់វា ។

ដោយកត់សំគាល់បន្ថែមថា វិធានការអភិរក្សក្រៅតំបន់ ដែលគួរអោយពេញចិត្តបំផុត គឺនៅក្នុងប្រទេសជាដើមកំណើតរបស់ប្រភេទ និងដើរតួនាទីយ៉ាងសំខាន់ ។

ដោយទទួលស្គាល់ថាការពឹងផ្អែកជាប្រពៃណីយ៉ាងជិតស្និទ្ធនៃសហគមន៍មូលដ្ឋាន និងជនជាតិដើម រួមទាំងការរស់នៅជាលក្ខណៈប្រពៃណីលើធនធានជីវៈចំរុះ និងភាពចង់បាននូវការចែករំលែកផលប្រយោជន៍ សហគមន៍ដែលចេញមកពីការប្រើប្រាស់ចំណេះដឹង ប្រពៃណី ការច្នៃប្រឌិត និងការអនុវត្តន៍ជាក់ស្តែងទាក់ទងទៅនឹងការអភិរក្សនៃធនធានជីវៈចំរុះ និងការប្រើប្រាស់ដោយនិរន្តរភាពនៃសមាសភាព របស់វា ។

ដោយកត់សំគាល់ផងដែរថា ស្ត្រីគួរបំពេញតួនាទីចាំបាច់ក្នុងការអភិរក្ស និងការប្រើប្រាស់ធនធានជីវៈចំរុះដោយនិរន្តរភាព និងអះអាងពីតំរូវការសំរាប់ការចូលរួមរបស់ស្ត្រីដោយពេញលេញនៅគ្រប់កំរិតធ្វើគោលនយោបាយ និងការអនុវត្តន៍សំរាប់ការអភិរក្សជីវៈចំរុះ ។

ដោយសង្កត់ធ្ងន់លើសារៈសំខាន់ និងសេចក្តីត្រូវការដើម្បីលើកស្ទួយសហប្រតិបត្តិការពិភពលោក តំបន់ និងអន្តរជាតិក្នុងចំណោមរដ្ឋ អង្គការក្នុងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលសំរាប់អភិរក្សនៃជីវៈចំរុះ និងការប្រើប្រាស់ដោយនិរន្តរភាពនៃសមាសភាពរបស់វា ។

ដោយទទួលស្គាល់ថាការផ្តល់នូវធនធានហិរញ្ញវត្ថុបន្ថែមជាថ្មី និងលទ្ធភាពត្រឹមត្រូវក្នុងការទទួលយកបច្ចេកវិទ្យាពាក់ព័ន្ធ ដែលរំពឹងទុកថានឹងធ្វើអោយមានការខុសប្លែកច្រើន ខាងសមត្ថភាពពិភពលោកដើម្បីដោះស្រាយបញ្ហាបាត់បង់ជីវៈចំរុះ ។

ដោយទទួលស្គាល់បន្ថែមថាការផ្តល់ធនធានពិសេសៗ គឺចាំបាច់ដើម្បីឆ្លើយតបនឹងតំរូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ រួមមានការផ្តល់នូវធនធានហិរញ្ញវត្ថុបន្ថែមជាថ្មី និងលទ្ធភាពសមស្របក្នុងការទទួលយកបច្ចេកវិទ្យាពាក់ព័ន្ធ ។

ដោយកត់សំគាល់ឃើញនៅក្នុងរឿងនេះមានលក្ខខណ្ឌពិសេសសំរាប់ប្រទេសអភិវឌ្ឍន៍តិចតួច និងបណ្តារដ្ឋជាកោះ ។

ដោយទទួលស្គាល់ថាការវិនិយោគធំៗ ត្រូវការដើម្បីអភិរក្សជីវៈចំរុះហើយដែលមានការរំពឹងទុកមើលផលប្រយោជន៍សង្គមសេដ្ឋកិច្ច និងបរិស្ថានជាទូលំទូលាយពីការវិនិយោគនោះ ។

ដោយទទួលស្គាល់ថាការអភិវឌ្ឍន៍សង្គម, សេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រ គឺជាអាទិភាពទី១នៃប្រទេសកំពុងអភិវឌ្ឍន៍ ។

ដោយយល់ដឹងការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះគឺមានសារៈសំខាន់សំរាប់ឆ្លើយតបនឹងតំរូវការ សុខភាព ម្ហូបអាហារ និងតំរូវការឯទៀតនៃប្រជាជនលើពិភពលោកដែលសំរាប់គោលដៅនេះហើយ ការចេញចូល និងការចែករំលែកទាំងធនធានសេនេទិច និងបច្ចេកវិទ្យាគឺចាំបាច់ ។

ដោយកត់សំគាល់ថា នៅទីបំផុតការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះនឹងពង្រឹងដល់ទំនាក់ទំនងជាមិត្តភាព ក្នុងបណ្តារដ្ឋនិងធ្វើភាគទានដល់សន្តិភាពសំរាប់មនុស្សលោក ។

ដោយប្រាថ្នាចង់បានដើម្បីធ្វើអោយប្រសើរ និងបន្ថែមលើកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់សំរាប់ការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ដោយនិរន្តរភាពនៃសមាសភាពរបស់វា និងដោយបានប្តេជ្ញាដើម្បីអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះសំរាប់ផលប្រយោជន៍ របស់មនុស្សបច្ចុប្បន្ន និងជំនាន់ក្រោយ :

*បានឯកភាពដូចតទៅ :*

## មាត្រាទី ១
## គោលបំណង

គោលបំណងនៃអនុសញ្ញានេះដើម្បីអនុវត្តអោយស្របជាមួយនឹងខាក់ព័ន្ធគឺការអភិរក្សជីវៈចំរុះ ការប្រើប្រាស់ដោយនិរន្តរភាពនៃសមាសភាពរបស់វា និងការចែករំលែកផលប្រយោជន៍អោយបានសមធម៌ចេញមកពីការប្រើប្រាស់ នៃធនធានសេនេទិចរួមទាំងសិទ្ធិប្រើប្រាស់សមស្របដល់ធនធានសេនេទិច ការផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធអោយបានសមរម្យដោយគិតទាំងសិទ្ធិទាំងអស់លើធនធាន និងបច្ចេកវិទ្យាទាំងនោះ និងដោយមានការផ្តល់មូលនិធិសមស្រប ។

## មាត្រាទី ២
## ការប្រើប្រាស់ពាក្យ

-សំរាប់គោលបំណងនៃអនុសញ្ញានេះ :

"ជីវៈចំរុះ" មានន័យថាភាពសំបូរបែបនៃសារពាង្គកាយមានជីវិតមកពីគ្រប់ប្រភព រួមមានប្រព័ន្ធអេកូឡូស៊ីដីគោក, ពិភពសមុទ្រ ទឹកដទៃទៀត និងប្រព័ន្ធអេកូឡូស៊ីទាំងមូលដែលសារពាង្គកាយមានជីវិតទាំងនោះ រស់នៅក្នុងរួមទាំងភាពសំបូរក្នុងប្រភេទ រវាងប្រភេទ ក្នុងប្រព័ន្ធអេកូឡូស៊ី ។

"ធនធានជីវៈចំរុះ" រួមបញ្ចូលធនធានសេនេទិច សារពាង្គកាយ ឬផ្នែកនៃសារពាង្គកាយ ចំនួនហ្វូង ឬផ្នែកមានជីវិតនៃប្រព័ន្ធអេកូឡូស៊ី ដោយមានការប្រើប្រាស់ផ្ទាល់ ឬជាក់ស្តែង ឬមានតំលៃសំរាប់មនុស្សលោក ។

"ជីវបច្ចេកវិទ្យា" ការអនុវត្តគតិបច្ចេកវិទ្យា ដែលប្រើប្រាស់ប្រព័ន្ធជីវសាស្ត្រសារពាង្គកាយរស់ ឬសារពាង្គកាយដែលវិវត្តន៍ចេញពីសារពាង្គកាយរស់នោះ ដើម្បីផ្លាស់ប្តូរផលិតផល ឬដំណើរការសំរាប់ការប្រើប្រាស់ដោយឡែកៗ ។

"ប្រទេសដែលជាដើមកំណើតនៃធនធានសេនេទិច" មានន័យថាប្រទេសជាម្ចាស់លើធនធានសេនេទិចទាំងនេះ ក្នុងលក្ខខណ្ឌក្នុងតំបន់ ‹ ក្នុងប្រទេស › ។

"ប្រទេសដែលផ្តល់ធនធានសេនេទិច" មានន័យថាប្រទេសផ្គត់ផ្គង់ធនធានសេនេទិចដែលប្រមូលបានពីប្រភពក្នុងស្រុក រួមទាំងចំនួនប្រភេទនៅក្នុងព្រៃ និងស្រុក ឬយកចេញពីប្រភពក្រៅស្រុកដែលអាច ឬមិនអាចមានប្រភពពីប្រទេសនោះ ។

"ប្រភេទបង្កាត់ថ្មី ឬធ្វើអោយក្លាយជាប្រភេទស្រុក" ជាប្រភេទដែលនៅក្នុងនោះដំណើរការវិវត្តន៍ទទួលរងឥទ្ធិពលពីមនុស្ស ដើម្បីឆ្លើយតបនឹងតំរូវការរបស់ខ្លួន ។

"ប្រព័ន្ធអេកូឡូស៊ី" ជាសហគមន៍ប្រព័ន្ធរុក្ខជាតិ សត្វ និងមីក្រូសារពាង្គកាយ និងបរិស្ថានគ្មានជីវិតរបស់វាដែលធ្វើប្រតិកម្ម ទៅវិញទៅមក និងជាផ្នែកមួយដែលមានមុខងារច្បាស់លាស់ ។

"ការអភិរក្សក្រៅតំបន់" ជាការអភិរក្សនៃសមាសភាពជីវៈចំរុះនៅក្រៅដែនជំរកធម្មជាតិ ។

"សំភារៈសេនេទិច" ជាសំភារៈរុក្ខជាតិ សត្វ មីក្រូប ឬសរីរាង្គដទៃទៀតដែលជាអង្គទទួលមរតក ។

"ធនធានសេនេទិច" ជាសំភារៈសេនេទិចដែលមានតំលៃខ្ពស់ ឬជាក់ស្តែង ។

"ដែនជំរក" ជាកន្លែង ឬប្រភេទនៃទីកន្លែងដែលសារពាង្គកាយ ឬចំនួនហ្វូងកើតមានតាមលក្ខណៈធម្មជាតិ ។

"លក្ខខណ្ឌក្នុងតំបន់" ជាលក្ខខណ្ឌដែលធនធានសេនេទិច វត្តមាននៅក្នុងប្រព័ន្ធអេកូឡូស៊ី និងដែនជំរកធម្មជាតិ និងក្នុងកន្លែងជុំវិញដែលវាបានវិវឌ្ឍលក្ខណៈប្លែកៗរបស់ពួកវា ក្នុងករណីប្រភេទដែលត្រូវប្រែក្លាយទៅជាប្រភេទក្នុងស្រុក ឬបង្កាត់បណ្តុះបណ្តាលឡើង ។

"ការអភិរក្សក្នុងតំបន់" ជាការអភិរក្សនៃប្រព័ន្ធអេកូឡូស៊ី និងដែនជំរកធម្មជាតិ ថែរក្សា និងស្តារឡើងវិញនូវចំនួនប្រភេទដែលមានជីវិតនៅក្នុងបរិស្ថានធម្មជាតិ និងក្នុងបរិដ្ឋានជុំវិញដែលប្រភេទទាំងនោះបានវិវឌ្ឍន៍មានលក្ខណៈខុសៗគ្នាសំរាប់ប្រភេទ ដែលត្រូវប្រែក្លាយអោយទៅជាប្រភេទស្រុក ឬប្រភេទដែលត្រូវបង្កាត់ ឬបណ្តុះបណ្តាលឡើង ។

"តំបន់ការពារធម្មជាតិ" ជាតំបន់ត្រូវកំណត់ឡើងតាមលក្ខណៈភូមិសាស្ត្រដែលបានបង្កើតនិង គ្រប់គ្រងដើម្បីសំរេចនូវគោលបំណងអភិរក្សដោយឡែកៗ ។

"អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់" ជាអង្គការបង្កើតដោយបណ្តារដ្ឋអធិបតេយ្យនៅក្នុងតំបន់ដែលនៅក្នុងនោះរដ្ឋជាសមាជិកបានផ្ទេរសមត្ថភាពលើបញ្ហាពាក់ព័ន្ធគ្រប់គ្រងដោយអនុសញ្ញានេះ និងត្រូវបានផ្តល់ដែនសមត្ថកិច្ចដើម្បីចុះហត្ថលេខា តាមរយៈការផ្តល់សច្ចាប័ន ព្រមព្រៀងទទួលយក យល់ព្រមឬ ផ្តល់សិទ្ធិចូលទៅក្នុងអនុសញ្ញាដោយមានការឯកភាពជាមួយបែបបទផ្ទៃក្នុង ។

"ការប្រើប្រាស់ដោយនិរន្តរភាព" ជាការប្រើប្រាស់សមាសភាពនៃជីវៈចំរុះក្នុងវិធី និងនៅអត្រាមួយដែលមិននាំទៅរកការខ្ជះខាតយូរអង្វែងនៃជីវៈចំរុះ ដោយធានាថែរក្សាសក្តានុពលរបស់វា ដើម្បីឆ្លើយតបទៅនឹងតំរូវការ និងក្តីប្រាថ្នាដ៏ច្រើននៃជំនាន់បច្ចុប្បន្ន និងអនាគត ។

"បច្ចេកវិទ្យា" រួមបញ្ចូលផងដែរនូវជីវបច្ចេកវិទ្យា ។

## មាត្រា ៣

## គោលការណ៍

ដោយស្របគ្នាជាមួយនឹងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ និងគោលការណ៍នៃច្បាប់អន្តរជាតិ រដ្ឋមានសិទ្ធិអធិបតេយ្យ ដើម្បីធ្វើអាជីវកម្មនៃធនធានរបស់គេស្របគ្នាទៅនឹងគោលនយោបាយបរិស្ថានរបស់រដ្ឋនោះ និងភាពទទួលខុសត្រូវដើម្បីធានាថាសកម្មភាពនានាស្ថិតនៅក្នុងក្របខ័ណ្ឌដែនសមត្ថកិច្ចរបស់ខ្លួន ឬការត្រួតពិនិត្យពុំបណ្តាលអោយខូចខាតដល់បរិស្ថានរបស់រដ្ឋនៅក្រៅព្រំប្រទល់នៃដែនសមត្ថកិច្ចជាតិ ។

## មាត្រា ៤

## វិសាលភាពនៃដែនសមត្ថកិច្ច

ប្រធានបទទាក់ទងទៅនឹងសិទ្ធិរបស់រដ្ឋដទៃ និងលើកលែងតែបានបញ្ជាក់នៅក្នុងអនុសញ្ញានេះទំនាក់ទំនងទៅនឹងភាគីចុះកិច្ចសន្យានីមួយៗអនុសញ្ញានេះអនុវត្តទៅលើ :

(ក) ក្នុងករណីសមាសភាពនៃជីវៈចំរុះក្នុងតំបន់នៅក្នុងព្រំប្រទល់នៃដែនសមត្ថកិច្ចជាតិ ។

(ខ) ក្នុងករណីនៃដំណើរការ និងសកម្មភាពនានាដោយមិនគិតពីកន្លែងដែលផលប៉ះពាល់កើតមានឡើងត្រូវអនុវត្តនៅក្រោម ដែនសមត្ថកិច្ច ឬការត្រួតពិនិត្យ នៅក្នុងតំបន់ដែនសមត្ថកិច្ចជាតិ ឬនៅក្រៅព្រំប្រទល់នៃដែនសមត្ថកិច្ចជាតិ ។

## មាត្រា ៥

## សហប្រតិបត្តិការ

ដរាបណាធ្វើទៅបាន និងសមហេតុផលភាគីចុះកិច្ចសន្យានីមួយៗ ត្រូវសហប្រតិបត្តិការជាមួយភាគីចុះកិច្ចសន្យានានា ដោយផ្ទាល់ នូវកន្លែងសមស្របតាមរយៈអង្គការអន្តរជាតិមានសមត្ថភាពទាក់ទងទៅនឹងតំបន់នៅក្រៅដែនសមត្ថកិច្ច និងលើបញ្ហាដទៃទៀតនៃផលប្រយោជន៍រួមសំរាប់ការប្រើប្រាស់ដោយនិរន្តរភាព និងអភិរក្សនៃជីវៈចំរុះ ។

## មាត្រា ៦

## ចំណាត់ការទូទៅសំរាប់អភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាព

ដោយស្របនឹងលក្ខខណ្ឌពិសេសៗ និងសមត្ថភាព ភាគីចុះកិច្ចសន្យានីមួយៗត្រូវ :

(ក) បង្កើតកម្មវិធីផែនការ ឬយុទ្ធសាស្ត្រជាតិសំរាប់ការអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ឬសំរបទៅតាមគោលដៅនេះ កម្មវិធី ផែនការ ឬយុទ្ធសាស្ត្រនានា ត្រូវឆ្លុះបញ្ចាំងពីវិធានការដែលកំនត់នៅក្នុងអនុសញ្ញានេះពាក់ព័ន្ធទៅនឹងការបារម្ភរបស់ភាគីចុះកិច្ចសន្យា ។

(ខ) ដរាបណាធ្វើទៅបាននិងសមស្រប ធ្វើសមាហរណកម្មការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សជីវៈចំរុះនៅក្នុងគោលនយោបាយកម្មវិធី និងផែនការតាមផ្នែកពាក់ព័ន្ធ ។

## មាត្រាទី ៧
## អត្តសញ្ញាណ និងការតាមឃ្លាំមើល

ដរាបណាអាចធ្វើទៅបាន និងត្រឹមត្រូវជាពិសេសសំរាប់គោលបំណងនៃមាត្រាទី៨ ដល់ទី១០ ភាគីចុះកិច្ចសន្យានីមួយៗត្រូវ :

(ក) ធ្វើអត្តសញ្ញាណកម្ម សមាសភាពនៃជីវៈចំរុះដែលមានសារៈសំខាន់សំរាប់ការប្រើប្រាស់ដោយនិរន្តរភាព និងអភិរក្សដែលពាក់ចងទៅនឹងបញ្ជីសន្ទស្សន៍របស់លំដាប់ថ្នាក់បានកំណត់ក្នុងឧបសម្ព័ន្ធ ១ ។

(ខ) តាមឃ្លាំមើល តាមរយៈការយកវត្ថុភាគ ឬបច្ចេកទេសដទៃទៀតចូលសមាសភាពនៃជីវៈចំរុះដែលបានកំណត់រួច អនុលោមទៅតាមអនុកថាខ័ណ្ឌ (ក)ខាងលើ ធ្វើការប្រុងប្រយ័ត្នលើវិធានការអភិរក្សបន្ទាន់ដែលផ្តល់នូវសក្តានុពលខ្លាំងក្លាសំរាប់ការប្រើប្រាស់ដោយនិរន្តរភាព។

(គ) ធ្វើអត្តសញ្ញាណដំណើរការ និងលំដាប់ថ្នាក់នៃសកម្មភាពដែលទំនងជាមានផលប៉ះពាល់អាក្រក់ដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចំរុះដោយនិរន្តរភាព និងតាមឃ្លាំមើលផលប៉ះពាល់នោះតាមរយៈយកវត្ថុភាគ និងបច្ចេកទេសដទៃទៀត ។

(ឃ) ថែរក្សា និងរៀបចំជាទិន្នន័យយន្តការដែលទទួលបានពីសកម្មភាពតាមឃ្លាំមើល និងអត្តសញ្ញាណកម្ម ដោយផ្អែកលើអនុកថាខ័ណ្ឌ (ក),(ខ) និង(គ)ខាងលើ ។

## មាត្រាទី ៨
## ការអភិរក្សក្នុងតំបន់

ដរាបណាអាចធ្វើទៅបាន និងត្រឹមត្រូវ ភាគីចុះកិច្ចសន្យាត្រូវ :

(ក) បង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិ ឬតំបន់ណាដែលចាំបាច់ត្រូវមានវិធានការពិសេសដើម្បីអភិរក្ស ជីវៈចំរុះ ។

(ខ) នៅកន្លែងដែលចាំបាច់ បង្កើតគោលការណ៍ណែនាំសំរាប់ជ្រើសរើស បង្កើត និងរៀបចំគ្រប់គ្រងតំបន់ការពារធម្មជាតិ ឬតំបន់នានា ដែលតំរូវអោយមានវិធានការពិសេសដើម្បីអភិរក្សជីវៈចំរុះ ។

(គ) រៀបចំគ្រប់គ្រងធនធានជីវៈចំរុះដែលមានសារៈសំខាន់សំរាប់អភិរក្សជីវៈចំរុះ ទោះបីនៅក្នុង ឬក្រៅតំបន់ការពារធម្មជាតិ ដោយមានទស្សនៈច្បាស់លាស់ដើម្បីធានាបាននូវការអភិរក្ស និងប្រើប្រាស់ដោយនិរន្តរភាព ។

(ឃ) លើកកំពស់កិច្ចការពារនៃប្រព័ន្ធអេកូឡូស៊ី ដែនជំរកធម្មជាតិ និងថែរក្សានូវចំនួនប្រភេទដែលមានសារៈសំខាន់នៅក្នុងមជ្ឈដ្ឋានធម្មជាតិជុំវិញ ។

(ង) លើកស្ទួយការអភិវឌ្ឍន៍ដោយចីរភាព និងមានលក្ខណៈបរិស្ថាននៅក្នុងតំបន់ជាប់នឹងតំបន់ការពារធម្មជាតិដោយមានទស្សនៈផ្តល់កិច្ចការពារបន្ថែមដល់តំបន់ទាំងនេះ ។

(ច) ស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលខូចខាត និងលើកស្ទួយការស្តារឡើងវិញនៃប្រភេទត្រូវទទួលរងការគំរាមកំហែង តាមរយៈការអភិវឌ្ឍន៍ និងអនុវត្តផែនការ ឬយុទ្ធសាស្ត្រគ្រប់គ្រងដទៃទៀត ។

(ឆ) បង្កើតឬ បន្តថែរក្សាមធ្យោបាយដើម្បីរៀបចំគ្រប់គ្រងឬ កាត់បន្ថយគ្រោះថ្នាក់ដែលជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ និងការបញ្ចេញនូវសារពាង្គកាយកែច្នៃរស់ (LMO) បណ្តាលមកពីជីវបច្ចេកវិទ្យាដែលទំនងជាមានផលប៉ះពាល់អាក្រក់ដល់បរិស្ថាន និងអាចប៉ះពាល់ដល់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ដោយរាប់បញ្ចូលផងដែរនូវគ្រោះថ្នាក់ដល់សុខភាពមនុស្ស ។

(ជ) ការរារាំងការនាំចូល ត្រួតពិនិត្យឬ លុបបំបាត់ប្រភេទមកពីក្រៅដែលគំរាមកំហែងដល់ប្រព័ន្ធអេកូឡូស៊ីដែនជំរក ឬប្រភេទ ។

(ឈ) ព្យាយាមបង្កើតលក្ខណៈសមត្ថភាព ដើម្បីផ្តល់លក្ខខណ្ឌត្រូវការសំរាប់ភាពស៊ីសង្វាក់គ្នារវាងការប្រើប្រាស់បច្ចុប្បន្ន និងការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ផ្នែកនៃជីវៈចំរុះ ។

(ញ) ការអភិរក្សក្នុងតំបន់នឹងជាប្រធានបទសំរាប់ដោយមិនខ្វះភាពច្បាប់ជាតិ គោរពថែរក្សា និងធានាបាននូវចំណេះដឹងការច្នៃប្រឌិត និងការអនុវត្តន៍របស់សហគមន៍មូលដ្ឋាន និងជនជាតិដើមទាំងរបៀបរស់នៅតាមប្រពៃណីសំរាប់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ និងលើកស្ទួយការអនុវត្តន៍របស់ពួកគេឲ្យបានទូលំទូលាយ ដោយមានការយល់ព្រមនិង ពាក់ព័ន្ធនៃម្ចាស់ចំណេះដឹង ការច្នៃប្រឌិត និងការអនុវត្តន៍បែបនោះ និងលើកទឹកចិត្តការបែងចែកផលប្រយោជន៍ស្មើគ្នាចេញពីការប្រើប្រាស់នៃការអនុវត្តន៍ច្នៃប្រឌិត និងចំណេះដឹងទាំងនោះ ។

(ដ) បង្កើត ឬធានាថែរក្សាច្បាប់ចាំបាច់ និងច្បាប់បរិស្ថានដទៃទៀតសំរាប់កិច្ចការពារនៃចំនួនពពួក និងប្រភេទដែលទទួលរងការគំរាមកំហែង ។

(ឋ) នៅកន្លែងដែលផលប៉ះពាល់អាក្រក់មកលើជីវៈចំរុះ ត្រូវបានកំណត់ដោយយោងទៅនឹងមាត្រា៧ រៀបចំគ្រប់គ្រងដំណើរការពាក់ព័ន្ធ និងសកម្មភាពនៃលំដាប់ថ្នាក់ ។

(ឌ) ធ្វើសហប្រតិបត្តិការក្នុងការផ្តល់ហិរញ្ញវត្ថុ និងផ្តល់ការផ្គត់ផ្គង់ដទៃទៀតសំរាប់ការអភិរក្សក្នុងតំបន់ដែលបញ្ជាក់នៅក្នុងអនុកថាខ័ណ្ឌ (ក) ដល់ (ឋ) ខាងលើជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ។

## មាត្រា ៩
## ការអភិរក្សក្រៅតំបន់

ដរាបណាការអាចធ្វើទៅបាន និងត្រឹមត្រូវ ជាពិសេសសំរាប់គោលបំណងបំពេញបន្ថែមវិធានការអភិរក្សក្នុងតំបន់ ភាគីចុះកិច្ចសន្យានីមួយៗត្រូវ :

(ក) អនុម័តវិធានការសំរាប់ការអភិរក្សក្រៅតំបន់នៃសមាសភាពរបស់ជីវៈចំរុះ ជាពិសេសនៅក្នុងប្រភេទដែលជាដើមកំណើតនៃសមាសភាពទាំងនោះ ។

(ខ) បង្កើត និងធានាថែរក្សាសំភារៈសំរាប់ការអភិរក្សក្រៅតំបន់ និងការស្រាវជ្រាវលើរុក្ខជាតិ សត្វនិង អតិសុខុមប្រាណ ជាពិសេសនៅក្នុងប្រទេសដែលជាដើមកំណើតនៃធនធានសេនេទិច ។

(គ) អនុម័តយកវិធានការសំរាប់ស្តារឡើងវិញនៃប្រភេទទទួលរងការគំរាមកំហែង និងសំរាប់កម្មវិធីនាំចូលប្រភេទទាំងនោះទៅក្នុងជំរកធម្មជាតិរបស់វានៅក្រោមលក្ខខណ្ឌសមស្រប ។

(ឃ) រៀបចំគ្រប់គ្រងប្រមូលធនធានជីវៈចំរុះ ពីជំរកធម្មជាតិសំរាប់គោលបំណងអភិរក្ស ក្រៅតំបន់ដើម្បីកុំឲ្យមានការគំរាមកំហែងដល់ប្រព័ន្ធអេកូឡូស៊ី និងប្រភេទក្នុងតំបន់លើកលែងតែកន្លែងណាមានវិធានការអភិរក្សក្រៅតំបន់បណ្តោះអាសន្នដែលបានចែងនៅក្នុងអនុកថាខ័ណ្ឌ (គ) ខាងលើ ។

(ង) ធ្វើសហប្រតិបត្តិការក្នុងការផ្តល់ហិរញ្ញវត្ថុ និងផ្តល់ការផ្គត់ផ្គង់ដទៃទៀតសំរាប់ការអភិរក្សក្រៅតំបន់ដែលបញ្ជាក់ នៅក្នុងអនុកថាខ័ណ្ឌ (ក) ដល់ (ឃ) ខាងលើ និងក្នុងការបង្កើត និងថែរក្សានៃសំភារៈអភិរក្សក្រៅតំបន់ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

## មាត្រា ១០

## ការប្រើប្រាស់ដោយនិរន្តរភាពនៃសមាសភាពរបស់ជីវៈចំរុះ

ដរាបណាអាចធ្វើទៅបាន និងត្រឹមត្រូវ ភាគីចុះកិច្ចសន្យានីមួយៗត្រូវ :

(ក) ធ្វើសមាហរណកម្មការពិចារណាលើការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សធនធានជីវសាស្ត្រទៅក្នុងការធ្វើសេចក្តីសំរេចថ្នាក់ជាតិ ។

(ខ) អនុម័តវិធានការពាក់ព័ន្ធទៅនឹងការប្រើប្រាស់ធនធានជីវសាស្ត្រដើម្បីជៀសវាង ឬកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អាក្រក់មកលើជីវៈចំរុះ ។

(គ) ការពារ និងលើកទឹកចិត្តការប្រើប្រាស់ជាលក្ខណៈទំនៀមទំលាប់នៃធនធានជីវសាស្ត្រអោយស្របជាមួយការអនុវត្តន៍វប្បធម៌ប្រពៃណីដែលស៊ីសង្វាក់នឹងការអភិរក្ស ឬតំរូវការប្រើប្រាស់ដោយនិរន្តរភាព ។

(ឃ) ផ្គត់ផ្គង់សហគមន៍មូលដ្ឋានដើម្បីបង្កើត និងអនុវត្តសកម្មភាពស្តារឡើងនៅក្នុងតំបន់ទទួលរងខូចខាតលើជីវៈចំរុះ ។

(ង) លើកទឹកចិត្តសហប្រតិបត្តិការរវាងអាជ្ញាធររដ្ឋាភិបាល និងផ្នែកឯកជនក្នុងការរៀបចំបង្កើតវិធីសាស្ត្រ សំរាប់ការប្រើប្រាស់ដោយនិរន្តរភាពនៃធនធានជីវសាស្ត្រ ។

## មាត្រា ១១

## វិធានការលើកទឹកចិត្ត

ដរាបណាអាចធ្វើទៅបាន និងត្រឹមត្រូវ ភាគីចុះកិច្ចសន្យានីមួយៗត្រូវអនុម័តវិធានការខាងលក្ខណៈសង្គម និងបរិស្ថានដែលជាគ្រឿងលើកទឹកចិត្តសំរាប់ការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សនៃសមាសភាពរបស់ជីវៈចំរុះ ។

## មាត្រា ១២

## ការស្រាវជ្រាវ និងការបណ្តុះបណ្តាល

ដោយគិតទាំងតំរូវការពិសេសៗរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ភាគីចុះកិច្ចសន្យាត្រូវ :

(ក) បង្កើត និងថែរក្សាកម្មវិធីសំរាប់ការបណ្តុះបណ្តាលការអប់រំបច្ចេកទេស និងវិទ្យាសាស្ត្រក្នុងវិធានការសំរាប់ធ្វើអត្តសញ្ញាណ ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ និងសមាសភាពរបស់វាហើយផ្តល់ការគាំទ្រសំរាប់ការបណ្តុះបណ្តាល និងការអប់រំបែបនោះសំរាប់តំរូវការពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

(ខ) លើកស្ទួយ និងលើកទឹកចិត្តស្រាវជ្រាវដែលផ្តល់វិភាគទានដល់ការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សនៃជីវៈចំរុះជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយអនុលោមទៅតាមសេចក្តីសំរេចរបស់សន្និសីទនៃភាគីចុះកិច្ចសន្យាដែលទទួលបានពីបាកនៃអនុសាសន៍របស់ក្រុមជំនួយការលើការផ្តល់យោបល់ខាងបច្ចេកវិទ្យាបច្ចេកទេស និងវិទ្យាសាស្ត្រ ។

(គ) ដោយប្រកាន់ខ្ជាប់ទៅនឹង "ខ" នៃមាត្រា ១៦, ១៨ និង២០ លើកកំពើង និងធ្វើសហប្រតិបត្តិការក្នុងការប្រើប្រាស់នៃការរីកចំរើនមុខវិទ្យាសាស្ត្រខាងការស្រាវជ្រាវជីវៈចំរុះ ក្នុងវិធីសាស្ត្រកំពុងអភិវឌ្ឍន៍សំរាប់ការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សនៃធនធានជីវសាស្ត្រ ។

## មាត្រា ១៣
## ការយល់ដឹង និងការអប់រំសាធារណៈ

ភាគីចុះកិច្ចសន្យាត្រូវ :

(ក) លើកស្ទួយ និងជំរុញអោយមានការយល់ដឹងពីសារៈសំខាន់ និងតំរូវការវិធានការសំរាប់ការអភិរក្សនៃជីវៈចំរុះព្រមទាំងធ្វើការផ្សព្វផ្សាយតាមបណ្តាញឃោសនា និងបញ្ចូលប្រធានបទទាំងនោះទៅក្នុងកម្មវិធីអប់រំ ។

(ខ) ធ្វើសហប្រតិបត្តិការអោយបានត្រឹមត្រូវជាមួយរដ្ឋដទៃទៀត និងអង្គការអន្តរជាតិក្នុងការបង្កើតកម្មវិធីយល់ដឹងសាធារណៈ និងអប់រំដោយផ្តោតទៅលើការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សនៃជីវៈចំរុះ ។

## មាត្រា ១៤
## ការវាយតំលៃផលប៉ះពាល់ និងការកាត់បន្ថយអប្បបរមានូវផលប៉ះពាល់អាក្រក់

១. តាមដែលអាចធ្វើទៅបាន និងត្រឹមត្រូវភាគីចុះកិច្ចសន្យានីមួយៗត្រូវ :

(ក) បង្ហាញពីបែបបទត្រឹមត្រូវ តំរូវអោយមានការវាយតំលៃផលប៉ះពាល់បរិស្ថាននៃគំរោងស្នើដែលទំនងជាមានផលប៉ះពាល់អាក្រក់ធ្ងន់ធ្ងរមកលើជីវៈចំរុះដើម្បីជៀសវាង ឬកាត់បន្ថយអប្បបរមានូវផលប៉ះពាល់នោះ ហើយនៅកន្លែងណាសមស្របអនុញ្ញាតិអោយមានការចូលរួមពីសាធារណៈក្នុងបែបបទនោះ ។

(ខ) បង្ហាញពីការរៀបចំចាត់ចែងត្រឹមត្រូវ ដើម្បីធ្វើអោយប្រាកដដល់ការទទួលខុសត្រូវលើផលបរិស្ថាននៃកម្មវិធី និងគោលនយោបាយនោះដែលទំនងជាមានផលប៉ះពាល់អាក្រក់លើជីវៈចំរុះ ។

(គ) ដោយឈរលើមូលដ្ឋានដូចគ្នាទៅវិញទៅមក លើកកំពស់ការជូនដំណឹង ផ្លាស់ប្តូរពត៌មាន និងពិគ្រោះយោបល់លើសកម្មភាពនានាស្ថិតនៅក្រោមដែនសមត្ថកិច្ច ឬការត្រួតពិនិត្យដែលទំនងជាមានផលប៉ះពាល់អាក្រក់មកលើជីវៈចំរុះនៃបណ្តារដ្ឋដទៃទៀត ឬតំបន់ដែលស្ថិតនៅខាងក្រៅព្រំប្រទល់នៃដែនសមត្ថកិច្ចជាតិ ដោយជំរុញអោយមានការបញ្ចប់នៃកិច្ចព្រមព្រៀងពហុភាគីតំបន់ ឬទ្វេភាគីបានត្រឹមត្រូវ ។

(ឃ) ក្នុងករណីគ្រោះថ្នាក់ ឬការខូចខាតជិតកើតមានឡើងនៅក្រោមដែនសមត្ថកិច្ច និងការត្រួតពិនិត្យជីវៈចំរុះ នៅក្នុងតំបន់ក្រោមដែនសមត្ថកិច្ចរបស់រដ្ឋដទៃទៀត ឬនៅក្នុងតំបន់ក្រៅព្រំប្រទល់នៃដែនសមត្ថកិច្ចជាតិ ធ្វើការជូនដំណឹងជាបន្ទាន់ដល់រដ្ឋដែលទទួលរងការខូចខាត ឬគ្រោះថ្នាក់ខ្លាំងក្លាព្រមទាំងផ្តួចផ្តើមសកម្មភាពដើម្បីការពារ ឬកាត់បន្ថយអប្បបរមានូវគ្រោះថ្នាក់ ឬការខូចខាតនោះ ។

(ង) លើកកំពស់ការរៀបចំចាត់ចែងថ្នាក់ជាតិសំរាប់ការឆ្លើយតបបន្ទាន់ទៅនឹងសកម្មភាព ឬព្រឹត្តិការណ៍នោះបើកើតមានពីធម្មជាតិ ឬបណ្តាលពីសកម្មភាពដទៃទៀត ដែលបង្ហាញពីគ្រោះថ្នាក់ភ្លាមៗដល់ជីវៈចំរុះ និងជំរុញអោយមានកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីបន្ថែមលើកិច្ចខិតខំរបស់ជាតិក្នុងការបង្កើតផែនការសង្គ្រោះបន្ទាន់បែបមួយ ដោយមានការឯកភាពពីបណ្តារដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ។

(២). ដោយផ្អែកលើមូលដ្ឋាននៃការសិក្សាដែលនឹងរៀបចំធ្វើឡើង សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវត្រួតពិនិត្យ បញ្ហាការទទួលខុសត្រូវខាងផ្លូវច្បាប់ និងការកែតំរូវរួមទាំងការស្តារឡើងវិញ និងការសងសំណងការខូចខាតដល់ជីវៈចំរុះ លើកលែងតែការទទួលខុសត្រូវខាងផ្លូវច្បាប់ជាបញ្ហាផ្ទៃក្នុង ។

## មាត្រា ១៥
## សិទ្ធិប្រើប្រាស់ធនធានសេនេទិច

១. ដោយទទួលស្គាល់សិទ្ធិអធិបតេយ្យរបស់រដ្ឋលើធនធានធម្មជាតិ អាជ្ញាធរមានកំណត់សិទ្ធិប្រើប្រាស់ធនធានសេនេទិចរបស់រដ្ឋាភិបាលជាតិ និងត្រូវពាក់ព័ន្ធនឹងច្បាប់ជាតិ ។

២. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវព្យាយាមអោយអស់ពីសមត្ថភាពដើម្បីបង្កលក្ខខណ្ឌជួយសំរួលដល់សិទ្ធិប្រើប្រាស់ធនធានសេនេទិច ដែលមានលក្ខណៈបរិស្ថានដោយភាគីចុះកិច្ចសន្យាដទៃទៀត និងមិនត្រូវដាក់កំហិតដើម្បីអោយឆ្លើយតបទៅនឹងអនុសញ្ញានេះឡើយ ។

៣. សំរាប់គោលបំណងនៃអនុសញ្ញានេះ យោងទៅនឹងមាត្រានេះ មាត្រា១៦ និង១៩ ធនធានសេនេទិច ដែលផ្តល់ដោយភាគីចុះកិច្ចសន្យា ជាធនធានមានប្រភពពីប្រទេសដែលជាដើមកំណើតរបស់ធនធាននោះ ឬពីប្រទេសដែលទទួលយកធនធានសេនេទិច ដោយអនុលោមតាមអនុសញ្ញានេះ ។

៤. នៅទីកន្លែងណាដែលបានទទួល សិទ្ធិប្រើប្រាស់ត្រូវ តែឯកភាពជាលាយល័ក្ខអក្សរ និងយោងតាម "ខ" នៃមាត្រានេះ ។

៥. សិទ្ធិប្រើប្រាស់ធនធានសេនេទិច ត្រូវតែឯកភាពមុនការព្រមព្រៀងដោយមានការជូនដំណឹងដល់ភាគីចុះកិច្ចសន្យាដែលផ្តល់ធនធាននោះ ប្រសិនបើមិនត្រូវបានកំណត់ដោយភាគីនោះទេ ។

៦. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវព្យាយាមអោយអស់ពីសមត្ថភាពដើម្បីរៀបចំបង្កើត និងអនុវត្តការស្រាវជ្រាវវិទ្យាសាស្ត្រផ្អែកលើធនធានសេនេទិចដែលផ្តល់ដោយភាគីចុះកិច្ចសន្យាដទៃទៀត ដោយមានការចូលរួមពេញលេញរបស់ភាគីចុះកិច្ចសន្យានោះ នៅទីកន្លែងណាដែលអាចធ្វើទៅបាន ។

៧. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវចាត់វិធានការច្បាប់ រដ្ឋបាល ឬនយោបាយអោយបានត្រឹមត្រូវ និងសមស្របនឹងមាត្រា១៦ និង១៩ តាមរយៈយន្តការហិរញ្ញវត្ថុបានបង្កើតដោយមាត្រា២០ និង២១ ដែលមានគោលដៅចែករំលែកលទ្ធផលនៃការស្រាវជ្រាវ និងការអភិវឌ្ឍន៍អោយបានសមធម៌ យុត្តិធម៌ និងចែករំលែកផលប្រយោជន៍បានមកពីពាណិជ្ជកម្ម និងការប្រើប្រាស់នៃធនធានសេនេទិចជាមួយភាគីចុះកិច្ចសន្យាដែលផ្តល់ធនធាននោះ ។ ការចែករំលែកនោះត្រូវមានការឯកភាពគ្នាទៅវិញទៅមកជាលាយល័ក្ខអក្សរ ។

## មាត្រា ១៦
## សិទ្ធិប្រើប្រាស់ និងផ្ទេរបច្ចេកវិទ្យា

១. ដោយទទួលស្គាល់ថា បច្ចេកវិទ្យារួមទាំងជីវបច្ចេកវិទ្យាសិទ្ធិប្រើប្រាស់ និងផ្ទេរបច្ចេកវិទ្យាទាំងពីរក្នុងចំណោមភាគីចុះកិច្ចសន្យា គឺជាឧបករណ៍ចាំបាច់សំរាប់សំរេចបាននូវគោលបំណងនៃអនុសញ្ញានេះ ភាគីចុះកិច្ចសន្យានីមួយៗត្រូវឯកភាពទៅនឹង "ខ" នៃមាត្រានេះ ដើម្បីនឹងជួយសំរួលសិទ្ធិប្រើប្រាស់ និងផ្ទេរបច្ចេកវិទ្យាដល់ភាគីចុះកិច្ចសន្យាដទៃទៀតដែលទាក់ទងនឹងការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សនៃជីវៈចំរុះ ឬការទាញយកផលប្រយោជន៍នៃធនធានសេនេទិច ហើយមិនបណ្តាលអោយមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន ។

២. សិទ្ធិប្រើប្រាស់ និងផ្ទេរបច្ចេកវិទ្យាដោយយោងទៅនឹងកថាខ័ណ្ឌ ១ខាងលើ ត្រូវផ្តល់ ឬជួយសំរួលដល់ប្រទេសកំពុងអភិវឌ្ឍន៍ នៅ ក្រោមលក្ខខណ្ឌយោគយល់បំផុត និងយុត្តិធម៌រួមទាំងការធ្វើសម្បទានដោយមានឯកភាពទាំងសងខាង និងចាំបាច់អោយស្របគ្នានឹងយន្តការហិរញ្ញវត្ថុដែលបង្កើតដោយមាត្រា២០ និង២១ ។ ក្នុងករណីបច្ចេកវិទ្យាត្រូវអោយមានបង់ប៉ាតង់ និងទ្រព្យកម្មសិទ្ធិមានតំលៃខ្ពស់

ការផ្ទេរ និងសិទ្ធិប្រើប្រាស់នោះ ត្រូវផ្តល់អោយក្នុងលក្ខខណ្ឌដែលទទួលស្គាល់ និងស្របគ្នាជាមួយកិច្ចការពារមានប្រសិទ្ធភាព និងត្រឹមត្រូវរបស់ទ្រព្យ កម្មសិទ្ធិមានតំលៃខ្ពស់ការអនុវត្តន៍កថាខ័ណ្ឌនេះ ត្រូវឯកភាពគ្នានឹងកថាខ័ណ្ឌ ៣.៤ និង៥ខាងក្រោម ។

៣. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវចាត់វិធានការ ច្បាប់រដ្ឋបាល ឬនយោបាយអោយបានសមស្របដោយមានគោលដៅផ្តល់សិទ្ធិប្រើប្រាស់ និងផ្ទេរបច្ចេកវិទ្យាប្រើប្រាស់ធនធានទាំងនោះដល់ភាគីចុះកិច្ចសន្យា ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ដែលផ្តល់ធនធានសេនេទិច រួមទាំងបច្ចេកវិទ្យាដែលត្រូវការពារដោយប៉ាតង់ និងទ្រព្យកម្មសិទ្ធិមានតំលៃខ្ពស់ដទៃទៀត នៅពេលដែលចាំបាច់តាមរយៈ ខ មាត្រា ២០. ២១ និងអនុលោមទៅតាមច្បាប់អន្តរជាតិ ហើយស្របនឹងកថាខ័ណ្ឌ ៤ និង៥ខាងក្រោម ។

៤. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវចាត់វិធានការច្បាប់រដ្ឋបាល និងនយោបាយអោយបានសមស្របដោយមានគោលដៅថាផ្នែកឯកជន ជួយសំរួលសិទ្ធិប្រើប្រាស់ការអភិវឌ្ឍន៍រួម និងការផ្ទេរបច្ចេកវិទ្យាដែលបានយោងទៅនឹងកថាខ័ណ្ឌ ១ខាងលើសំរាប់ផលប្រយោជន៍នៃស្ថាប័នរដ្ឋាភិបាល និងផ្នែកឯកជននៃប្រទេសកំពុងអភិវឌ្ឍន៍ ហើយនៅក្នុងអត្ថន័យនេះត្រូវគោរពកាតព្វកិច្ចនៅក្នុងកថាខ័ណ្ឌ ១. ២ និង៣ ខាងលើ ។

៥. ដោយទទួលស្គាល់ថា ប៉ាតង់និង ទ្រព្យកម្មសិទ្ធិមានតំលៃខ្ពស់ដទៃទៀតអាចមានឥទ្ធិពលមក លើការអនុវត្តន៍នៃអនុសញ្ញានេះ ភាគីចុះកិច្ចសន្យាត្រូវធ្វើសហប្រតិបត្តិការក្នុងអត្ថន័យនេះ អោយបានសមស្របតាមច្បាប់អន្តរជាតិ និងច្បាប់ជាតិដើម្បីធ្វើអោយប្រាកដថាសិទ្ធិនោះ មានការគាំទ្រ និងមិនប្រឆាំងនឹងគោលបំណងរបស់វា ។

## មាត្រាទី ១៧
## ការដោះដូរនៃពត៌មាន

១. ភាគីចុះកិច្ចសន្យា ត្រូវជួយសំរួលការដោះដូរនៃពត៌មានពីគ្រប់ប្រភពដែលអាចទទួលបាន ទាក់ទងទៅនឹងការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះដោយគិតទាំងតំរូវការពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

២. យោងទៅនឹងមាត្រា១៦កថាខ័ណ្ឌ១ ការដោះដូរនៃពត៌មាននោះត្រូវរួមបញ្ចូល ការដោះដូរលទ្ធផលនៃការស្រាវជ្រាវសេដ្ឋកិច្ច-សង្គម វិទ្យាសាស្ត្រនិង បច្ចេកទេសព្រមទាំងពត៌មានអំពីកម្មវិធីចុះអង្កេត និងបណ្តុះបណ្តាលខាងចំណេះដឹងឯកទេស ចំណេះដឹងប្រពៃណី មូលដ្ឋាន និងរួមបញ្ចូលជាមួយបច្ចេកវិទ្យានានា ។ ការដោះដូរពត៌មាន ត្រូវបញ្ចូលការបញ្ជូននៃពត៌មានទៅវិញទៅមកផងដែរ តាមដែលអាចធ្វើទៅបាន ។

## មាត្រាទី ១៨
## កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេស

១. ភាគីចុះកិច្ចសន្យា ត្រូវលើកស្ទួយសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាអន្តរជាតិក្នុងផ្នែកអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះតាមរយៈវិទ្យាស្ថានជាតិ និងអន្តរជាតិសមរម្យ ។

២. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវលើកស្ទួយសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេសជាមួយភាគីចុះកិច្ចសន្យាដទៃទៀត ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តន៍អនុសញ្ញានេះ តាមរយៈការអនុវត្តន៍ និងអភិវឌ្ឍន៍នៃគោលនយោបាយជាតិ ។ ក្នុងការលើក ស្ទួយសហប្រតិបត្តិការបែបនោះគួរផ្តល់ការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពជាតិតាមមធ្យោបាយការអភិរក្សធនធានមនុស្ស និងការកសាងស្ថាប័ន ។

៣. ក្នុងកិច្ចប្រជុំដំបូង ភាគីចុះកិច្ចសន្យាត្រូវកំណត់វិធីបង្កើតយន្តការផ្ទេរក្បាល និងផ្សព្វផ្សាយព័ត៌មាន (CHM) ដើម្បីលើកស្ទួយ និងជួយសំរួលសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេស ។

៤. ដោយគោរពទៅតាមនយោបាយ ច្បាប់ជាតិ ភាគីចុះកិច្ចសន្យាត្រូវជំរុញ និងបង្កើតវិធីសាស្ត្រសហប្រតិបត្តិការ សំរាប់ការអភិវឌ្ឍន៍ និងការប្រើប្រាស់នៃបច្ចេកវិទ្យា រួមទាំងបច្ចេកវិទ្យាមានលក្ខណៈប្រពៃណី មូលដ្ឋានក្នុងការអនុវត្តន៍គោលបំណងនៃអនុសញ្ញានេះ ។ ក្នុងគោលដៅនេះ ភាគីចុះកិច្ចសន្យាត្រូវលើកតំកើនសហប្រតិបត្តិការខាងបណ្តុះបណ្តាលបុគ្គលិក និងការដោះដូរនៃអ្នកជំនាញការ ។

៥. ដោយមានការព្រមព្រៀងគ្នាភាគីចុះកិច្ចសន្យា ត្រូវលើកតំកើនការបង្កើតនៃកម្មវិធីស្រាវជ្រាវរួម និងការធ្វើពាណិជ្ជកម្មរួម សំរាប់ការអភិវឌ្ឍន៍នៃបច្ចេកវិទ្យាទាក់ទងនឹងគោលបំណងរបស់អនុសញ្ញានេះ ។

## មាត្រាទី ១៩

## ការគ្រប់គ្រងនៃជីវបច្ចេកវិទ្យា និងការចែករំលែកនៃផលប្រយោជន៍

១. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវចាត់វិធានការច្បាប់រដ្ឋបាល និងនយោបាយអោយបានត្រឹមត្រូវ ដើម្បីផ្តល់ការចូលរួមអោយមានប្រសិទ្ធភាព ក្នុងសកម្មភាពស្រាវជ្រាវជីវបច្ចេកវិទ្យាដោយភាគីចុះកិច្ចសន្យា ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ដែលផ្តល់ធនធានសេនេទិច សំរាប់ការស្រាវជ្រាវនោះ នៅទីកន្លែងដែលអាចធ្វើទៅបានក្នុងបណ្តាប្រទេសនៃភាគីចុះកិច្ចសន្យានោះ ។

២. ភាគីចុះកិច្ចសន្យានីមួយៗ ត្រូវចាត់វិធានការជាក់ស្តែងដើម្បីលើកតំកើង និងនាំមុខខាងសិទ្ធិប្រើប្រាស់ អាទិភាពទទួលទូវផល និងផលប្រយោជន៍ចេញពីជីវបច្ចេកវិទ្យាផ្អែកលើធនធានសេនេទិចផ្តល់ដោយភាគីចុះកិច្ចសន្យានោះ ដោយឈរលើមូលដ្ឋានស្មើភាព និងយុត្តិធម៌របស់ភាគីចុះកិច្ចសន្យាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ។ សិទ្ធិប្រើប្រាស់នោះត្រូវមានការឯកភាព ជាលាយល័ក្ខអក្សរ ។

៣. ភាគីចុះកិច្ចសន្យា ត្រូវពិចារណាពីតំរូវការ និងតំរូវនៃពិធីសារដែលកំណត់ឡើងពីបែបបទត្រឹមត្រូវរួមទាំង កិច្ចព្រមព្រៀង ជូនព័ត៌មានជាមុន ការផ្ទេរដោយសុវត្ថិភាពក្នុងការគ្រប់គ្រងនិង ការប្រើប្រាស់នៃសារពាង្គកាយរស់ត្រូវបានផ្លាស់ប្តូរ (LMO) ទទួលបានពីជីវ-បច្ចេកវិទ្យាដែលអាចមានផលប៉ះពាល់អាក្រក់លើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ។

៤. ដោយផ្ទាល់ ឬដោយតំរូវអោយអ្នកច្បាប់ ឬអ្នកធម្មជាតិ នៅក្រោមដែនសមត្ថកិច្ចដែលផ្តល់សារពាង្គកាយ អនុលោមទៅនឹងកថាខ័ណ្ឌ៣ខាងលើ ភាគីចុះកិច្ចសន្យានីមួយៗត្រូវផ្តល់ព័ត៌មានផ្សេងៗអំពីច្បាប់សុវត្ថិភាព និងប្រើប្រាស់ដែលតំរូវដោយភាគីចុះកិច្ចសន្យាក្នុងការគ្រប់គ្រងសារពាង្គកាយនោះព្រមទាំងព័ត៌មានដទៃទៀតអំពីផលប៉ះពាល់អាក្រក់នៃសារពាង្គកាយ ពិសេសទាក់ទងនឹងភាគីចុះកិច្ចសន្យាដែលនៅក្នុងនោះសារពាង្គកាយទាំងនោះត្រូវបាននាំចូល ។

## មាត្រាទី ២០

## ធនធានហិរញ្ញវត្ថុ

១. ដោយយោងទៅនឹងសមត្ថភាព ភាគីចុះកិច្ចសន្យានីមួយៗត្រូវទទួលខុសត្រូវផ្តល់គ្រឿងលើកទឹកចិត្ត និងការផ្គត់ផ្គង់ហិរញ្ញវត្ថុ ភាក់ទងទៅនឹងសកម្មភាពជាតិ ដែលមិនសំរេចគោលបំណងនៃអនុសញ្ញានេះស្របគ្នាជាមួយនឹងផែនការអាទិភាព និងកម្មវិធីជាតិ ។

២. ភាគីប្រទេសអភិវឌ្ឍន៍ ត្រូវផ្តល់ធនធានហិរញ្ញវត្ថុបន្ថែម និងថ្មីដើម្បីជំរុញភាគីប្រទេសកំពុងអភិវឌ្ឍន៍ឆ្លើយតបនឹងចំណាយបន្ថែមដល់ពួកគេ ក្នុងការអនុវត្តន៍ផែនការដែលបំពេញកាតព្វកិច្ចនៃអនុសញ្ញានេះ និងផលប្រយោជន៍បានមកពីការផ្តល់ហើយដែលការចំណាយនោះត្រូវបានព្រមព្រៀង ភាគីប្រទេសកំពុងអភិវឌ្ឍន៍ និងរចនាសម្ព័ន្ធស្ថាប័នដែលចែងនៅក្នុងមាត្រា២១ ដោយស្របគ្នានឹងលក្ខខ័ណ្ឌ:

ខាងនយោបាយ យុទ្ធសាស្ត្រកម្មវិធីអាទិភាព និងភាពស្របច្បាប់ និងបញ្ជីសន្ទស្សន៍នៃការចំណាយនោះ ដែលបានបង្កើតដោយសន្និសីទនៃភាគីចុះកិច្ចសន្យា ។ ភាគីដទៃទៀតរួមទាំងប្រទេសដែលកំពុងរៀបចំដំណើរការអន្តរកាលនៃសេដ្ឋកិច្ចទីផ្សារ អាចអនុវត្តដោយស្ម័គ្រចិត្តនូវកាតព្វកិច្ចរបស់ភាគីប្រទេសអភិវឌ្ឍន៍ ។ ក្នុងគោលបំណងនៃមាត្រានេះ ភាគីចុះកិច្ចសន្យាត្រូវបង្កើតបញ្ជីនៃភាគីប្រទេសអភិវឌ្ឍន៍ នៅពេលប្រជុំលើកដំបូង ហើយភាគីដទៃទៀតអនុវត្តដោយស្ម័គ្រចិត្តនូវកាតព្វកិច្ចនៃភាគីប្រទេសអភិវឌ្ឍន៍ ។ សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវត្រួតពិនិត្យកែសម្រួលតាម ពេលវេលាកំណត់មួយ ហើយប្រសិនបើចាំបាច់ត្រូវធ្វើវិសោធនកម្មបញ្ជីនោះ ។ គួរលើកទឹកចិត្តអោយមានវិភាគទានមកពីប្រទេសដទៃទៀត និងប្រភពផ្សេងដោយឈរលើមូលដ្ឋានស្ម័គ្រចិត្ត ។ ការអនុវត្តន៍នៃការងារនេះត្រូវគិតទាំងតម្រូវការសមរម្យ ការព្យាករណ៍ពីសកម្មភាពខាងមុខ និងការផ្តល់មូលនិធិទាន់ពេលកំណត់ និងសារៈសំខាន់នៃការចែករំលែកបន្ទុកក្នុងចំណោមភាគីធ្វើវិភាគទានរួមទាំងភាគីក្នុងបញ្ជីនេះផងដែរ ។

៣. ភាគីប្រទេសអភិវឌ្ឍន៍ អាចផ្តល់ធនធានហិរញ្ញវត្ថុដល់ភាគីប្រទេសកំពុងអភិវឌ្ឍន៍ទាក់ទងនឹងការអនុវត្តន៍នៃអនុសញ្ញានេះ តាមរយៈបណ្តាញពហុភាគីតំបន់ និងទ្វេភាគីដទៃទៀត ។

៤. ទំហំដែលភាគីប្រទេសកំពុងអភិវឌ្ឍន៍នឹងអនុវត្តដោយប្រសិទ្ធភាពនូវការប្តេជ្ញាចិត្តរបស់ខ្លួននៅក្រោមអនុសញ្ញានេះនឹងអាស្រ័យលើការអនុវត្តន៍ប្រសិទ្ធភាព ដោយភាគីប្រទេសអភិវឌ្ឍន៍នូវការប្តេជ្ញារបស់ខ្លួននៅក្រោមអនុសញ្ញានេះ ទាក់ទងទៅនឹងធនធានហិរញ្ញវត្ថុ និងការផ្លាស់ប្តូរបច្ចេកវិទ្យា ហើយនឹងពិចារណានូវការពិតដែលការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនិងការលុបបំបាត់ភាពក្រីក្រ គឺជាអាទិភាពដំបូងរបស់ភាគីប្រទេសកំពុងអភិវឌ្ឍន៍ ។

៥. ភាគីនានានឹងទទួលខុសត្រូវនូវសេចក្តីត្រូវការពិសេសៗ និងស្ថានភាពដោយឡែកៗនៃបណ្តាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចក្នុងសកម្មភាពលើការផ្តល់មូលនិធិ និងការផ្ទេរបច្ចេកវិទ្យា ។

៦. ភាគីចុះកិច្ចសន្យា ត្រូវពិចារណាលក្ខខណ្ឌពិសេសៗដែលទទួលបានពីការពឹងផ្អែកលើការចែករំលែក និងទីកន្លែងជីវៈចម្រុះនៅក្នុងភាគីប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសបណ្តារដ្ឋជាកោះតូចៗ ។

៧. ត្រូវយកចិត្តទុកដាក់ពិចារណាដល់ ស្ថានភាពពិសេសៗរបស់ប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងតំបន់ដែលមានការខូចខាតបរិស្ថាន ដូចជា នៅតំបន់ស្ងួតហួតហែង តំបន់ពាក់កណ្តាលស្ងួត តំបន់ភ្នំ និងតំបន់ឆ្នេរសមុទ្រ ។

## មាត្រា ២១

## យន្តការហិរញ្ញវត្ថុ

១.ត្រូវតែមានយន្តការមួយសំរាប់ការផ្តល់នៃធនធានហិរញ្ញវត្ថុដល់ភាគីប្រទេសកំពុងអភិវឌ្ឍន៍បំពេញគោលបំណងនៃអនុសញ្ញានេះលើមូលដ្ឋានសម្បទាន ឬអោយជាឥតប្រាក់ ផ្នែកចាំបាច់របស់វាបានពិពណ៌នានៅមាត្រានេះ ។ យន្តការនេះត្រូវដំណើរការនៅក្រោមអាជ្ញាធរ និងសេចក្តីណែនាំរបស់សន្និសីទនៃភាគីចុះកិច្ចសន្យាសំរាប់គោលបំណងនៃអនុសញ្ញានេះ ។ ប្រតិបត្តិការនៃយន្តការនឹងត្រូវអនុវត្តដោយរចនាសម្ព័ន្ធស្ថាប័នបែបនោះ ដូចដែលអាចសំរេចដោយសន្និសីទនៃភាគីចុះកិច្ចសន្យានៅក្នុងកិច្ចប្រជុំលើកដំបូង ។ សំរាប់គោលបំណងនៃអនុសញ្ញានេះ សន្និសិទនៃភាគីត្រូវកំណត់គោលនយោបាយយុទ្ធសាស្ត្រ លក្ខខ័ណ្ឌ: ភាពមានសិទ្ធិទទួលយក និងអាទិភាពទាក់ទងនឹងសិទ្ធិប្រើប្រាស់ និងការប្រើប្រាស់នៃធនធាន ។ ការធ្វើវិភាគទាន ត្រូវពិចារណាដល់តម្រូវការសំរាប់ភាពដែលអាចទស្សន៍ទាយបានភាពសមរម្យ និងចរាចរមូលនិធិទាន់ពេលវេលាដែលបានចែងនៅក្នុងមាត្រា២០ ស្របគ្នានឹងបរិមាណធនធានត្រូវការសំរាប់ធ្វើសេចក្តីសំរេចជាទៀងទាត់ដោយសន្និសីទនៃភាគីចុះកិច្ចសន្យា និងសារៈសំខាន់នៃការចែករំលែកបន្ទុកចំណោមភាគីផ្តល់វិភាគទាន រួមទាំង

បញ្ជីដែលបានស្រង់នៅក្នុងមាត្រា២០ កថាខ័ណ្ឌ២ ។ ការផ្តល់វិភាគទានដោយស្ម័គ្រចិត្តអាចធ្វើឡើងដោយភាគីប្រទេសអភិវឌ្ឍន៍ ដោយប្រទេសដទៃ និងប្រភពផ្សេងទៀត ។ យន្តការត្រូវប្រតិបត្តិនៅក្នុងប្រព័ន្ធអភិបាលកិច្ចតម្លាភាព និងប្រជាធិបតេយ្យ ។

២. យោងទៅនឹងគោលបំណងនៃអនុសញ្ញានេះ នៅក្នុងកិច្ចប្រជុំដំបូងសន្និសីទនៃភាគីចុះកិច្ចសន្យា ត្រូវកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងអាទិភាពកម្មវិធីនានាព្រមទាំងលក្ខន្តិកៈលំអិត និងគោលការណ៍ណែនាំសំរាប់សិទ្ធិដែលអាចជ្រើសរើសយកដើម្បីមានសិទ្ធិប្រើប្រាស់នៃធនធានហិរញ្ញវត្ថុរួមទាំងការតាមឃ្លាំមើល និងវាយតំលៃជាទៀងទាត់នៃការប្រើប្រាស់នោះ ។ សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវធ្វើសេចក្តីសំរេចចិត្តលើការរៀបចំ ដើម្បីផ្តល់ប្រសិទ្ធភាពដល់កថាខ័ណ្ឌ១ ខាងលើបន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយរចនាសម្ព័ន្ធស្ថាប័នដែលបានកំណត់ការទទួលខុសត្រូវលើប្រតិបត្តិការលើយន្តការហិរញ្ញវត្ថុ ។

៣. សន្និសីទនៃភាគីចុះកិច្ចសន្យា ត្រូវពិនិត្យកែសំរួលលើប្រសិទ្ធភាពនៃយន្តការដែលបានបង្កើតឡើងនៅក្រោមមាត្រានេះរួមទាំងលក្ខន្តិកៈ និងគោលការណ៍ណែនាំដែលមានចែងនៅក្នុងកថាខ័ណ្ឌ ២ខាងលើមិនតិចជាង២ឆ្នាំ បន្ទាប់ពីចូលជាសមាជិកនៃអនុសញ្ញានេះ ហើយបន្ទាប់ត្រូវធ្វើជាទៀងទាត់ ។ ដោយផ្អែកលើការពិនិត្យកែសំរួលនោះ ត្រូវចាត់វិធានការសមស្របដើម្បីលើកស្ទួយប្រសិទ្ធភាពនៃយន្តការប្រសិនបើចាំបាច់ ។

៤. ភាគីចុះកិច្ចសន្យា ត្រូវពិចារណាពង្រឹងស្ថាប័នហិរញ្ញវត្ថុដែលមានស្រាប់ដើម្បីផ្តល់ធនធានហិរញ្ញវត្ថុសំរាប់ការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះ ។

## មាត្រាទី ២២

## ទំនាក់ទំនងជាមួយអនុសញ្ញាអន្តរជាតិដទៃទៀត

១. ខ នៃអនុសញ្ញានេះមិនត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនៃភាគីចុះកិច្ចសន្យាណាមួយចេញពីកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់លើកលែងតែការអនុវត្តសិទ្ធិ និងកាតព្វកិច្ចទាំងនោះដែលនឹងបណ្តាលអោយមានការខូចខាតធ្ងន់ធ្ងរ ឬគំរាមកំហែងដល់ជីវៈចំរុះ ។

២. ភាគីចុះកិច្ចសន្យា ត្រូវអនុវត្តអនុសញ្ញានេះលើផ្នែកបរិស្ថានសមុទ្រអោយស្របនឹងច្បាប់ជាមួយសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋនៅក្រោមច្បាប់សមុទ្រ ។

## មាត្រាទី ២៣

## សន្និសីទនៃភាគីចុះកិច្ចសន្យា

១. សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវតែបង្កើតឡើង ។ កិច្ចប្រជុំដំបូងរបស់សន្និសីទរបស់ភាគីចុះកិច្ចសន្យាត្រូវរៀបចំដោយ នាយកប្រតិបត្តិនៃកម្មវិធីបរិស្ថានសហប្រជាជាតិមិនតិចជាង១ឆ្នាំបន្ទាប់ពីចូលជាសមាជិកនៃអនុសញ្ញានេះ ។ បន្ទាប់មកកិច្ចប្រជុំសាមញ្ញរបស់សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវរៀបចំឡើងជាទៀងទាត់ដែលនឹងកំនត់ដោយសន្និសីទនៅកិច្ចប្រជុំដំបូង ។

២. កិច្ចប្រជុំវិសាមញ្ញរបស់សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវរៀបចំឡើងនៅពេលវេលាណាមួយ ដែលកំណត់ដោយសន្និសីទ ឬធ្វើឡើងដោយភាគីណាមួយ ជូនដំណឹង៦ខែជាមុនដល់លេខាធិការដ្ឋានហើយ ដែលត្រូវគាំទ្រដោយយ៉ាងហោចណាស់សំលេង $^{1}/_{3}$ នៃភាគីចុះកិច្ចសន្យា ។

៣. សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវឯកភាពដោយមានការព្រមព្រៀងគ្នា និងអនុម័តបែបបទបរិធានសំរាប់ខ្លួនឯង និងក្រុមការងារជំនួយការនានា ដែលអាចត្រូវបង្កើតឡើងព្រមទាំងបទបញ្ញាហិរញ្ញវត្ថុសំរាប់គ្រប់គ្រងមូលនិធិរបស់លេខាធិការដ្ឋាន ។ នៅរាល់កិច្ចប្រជុំសាមញ្ញសន្និសីទនៃភាគីត្រូវអនុម័តថវិកាសំរាប់រយៈពេលកំណត់ណាមួយរហូតដល់កិច្ចប្រជុំសាមញ្ញបន្ទាប់មកទៀតត្រូវរៀបចំឡើង ។

៤. សន្និសីទនៃភាគីចុះកិច្ចសន្យាត្រូវធ្វើការពិនិត្យតាមដានចំពោះការអនុវត្តនៃអនុសញ្ញានេះ ហើយក្នុងគោលបំណងនេះសន្និសីទនៃភាគីត្រូវ :

(ក) បង្កើតទំរង់ និងពេលវេលាអន្តរកាលសំរាប់បញ្ជូនពត៌មានដែលនឹងត្រូវផ្ញើ យោងតាមមាត្រា២៦ និងពិចារណាពត៌មាននោះព្រមទាំងរបាយការណ៍ផ្ញើដោយក្រុមការងារជំនួយការ ។

(ខ) ធ្វើការពិនិត្យកែសំរួលយោបល់បច្ចេកវិទ្យាបច្ចេកទេស និងវិទ្យាសាស្ត្រលើជីវៈចំរុះដែលបានផ្តល់ផ្អែកតាមមាត្រា២៥ ។

(គ) តាមតំរូវការធ្វើការពិចារណា និងអនុម័តពិធីសារនានា យោងតាមមាត្រា២៨ ។

(ឃ) តាមតំរូវការធ្វើការពិចារណា និងអនុម័តវិសោធនកម្មនៃអនុសញ្ញានេះ និងឧបសម្ព័ន្ធរបស់វា យោងមាត្រា២៩ និង៣០ ។

(ង) ធ្វើការពិចារណា ការធ្វើវិសោធនកម្មនៃពិធីសារនានាព្រមទាំងឧបសម្ព័ន្ធរបស់វា ប្រសិនបើសំរេចបែបនេះធ្វើអនុសាសន៍ដល់ភាគីចុះកិច្ចសន្យាអោយអនុម័តពិធីសារនោះ ។

(ច) តាមតំរូវការធ្វើការពិចារណា និងអនុម័តឧបសម្ព័ន្ធបន្ថែមទៅនឹងអនុសញ្ញានេះ យោងលើមាត្រា៣០ ។

(ឆ) បង្កើតក្រុមការងារជំនួយការ ជាពិសេសដើម្បីផ្តល់យោបល់បច្ចេកទេស និងវិទ្យាសាស្ត្រដែលយល់ថាចាំបាច់ សំរាប់ការអនុវត្តន៍នៃអនុសញ្ញានេះ ។

(ជ) តាមរយៈលេខាធិការដ្ឋាន ធ្វើទំនាក់ទំនងជាមួយអង្គការប្រតិបត្តិនៃអនុសញ្ញាដើម្បីដោះស្រាយបញ្ហា ដែលចែងដោយអនុសញ្ញា ដោយមានទស្សនៈបង្កើតទំរង់បែបបទត្រឹមត្រូវនៃសហប្រតិបត្តិការជាមួយអង្គការប្រតិបត្តិ ។

(ឈ) ពិចារណា អនុវត្តសកម្មភាពបន្ថែមដែលអាចត្រូវការ សំរាប់សំរេចគោលបំណងនៃអនុសញ្ញានេះដើម្បីជាពន្លឺក្នុងការទទួលបទពិសោធន៍ក្នុងប្រតិបត្តិការនោះ ។

៥. អង្គការសហប្រជាជាតិ ទីភ្នាក់ងារឯកទេស និងទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិព្រមទាំងរដ្ឋដែលមិនមែនភាគីនៃអនុសញ្ញានេះ អាចផ្តល់តំណាងជាអ្នកសង្កេតការណ៍នៅរាល់កិច្ចប្រជុំនៃសន្និសីទភាគី ។ ទីភ្នាក់ងារ ឬអង្គការដទៃទៀត ទោះបីជាអង្គការរដ្ឋាភិបាល ឬក្រៅរដ្ឋាភិបាលដែលមានជំនាញខាងការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចំរុះដែលបានជូនពត៌មានដល់លេខាធិការដ្ឋានប្រាថ្នាចង់អោយអ្នកសង្កេតការណ៍របស់ខ្លួនទៅក្នុងសន្និសីទអាចអនុញ្ញាតអោយចូលបាន ប្រសិនបើគ្មានការជំទាស់ពីភាគីចុះកិច្ចសន្យា យ៉ាងហោចណាស់សំលេង $^{1}/_{3}$ ។ ការអនុញ្ញាតអោយចូលរួមនៃអ្នកសង្កេតការណ៍ ត្រូវតែគោរពទៅលើបទបញ្ជា បែបបទដែលអនុម័តដោយសន្និសីទនៃភាគី ។

## មាត្រាទី ២៤
## លេខាធិការដ្ឋាន

១. បន្ទាប់ពីលេខាធិការដ្ឋានត្រូវបានបង្កើត លេខាធិការដ្ឋាននេះត្រូវបំពេញតួនាទីដូចខាងក្រោម :

(ក) រៀបចំ និងផ្តល់សេវាកម្មសំរាប់កិច្ចប្រជុំរបស់សន្និសីទនៃភាគី យោងតាមមាត្រា ២៣ ។

(ខ) បំពេញមុខងារ និងតួនាទីដែលប្រគល់ជូនដោយពិធីសារនានា ។

(គ) រៀបចំរបាយការណ៍ស្តីពីការបំពេញមុខងាររបស់ខ្លួនក្រោមអនុសញ្ញានេះ និងផ្ញើជូនសន្និសីទនៃភាគីទុកពិចារណា ។

(ឃ) សំរបសំរួលជាមួយស្ថាប័នអន្តរជាតិពាក់ព័ន្ធនានា ជាពិសេសដើម្បីចូលទៅក្នុងប្រព័ន្ធរៀបចំរដ្ឋបាល ដូចដែលអាចត្រូវការ សំរាប់ការអនុវត្តន៍អោយមានប្រសិទ្ធភាពនៃមុខងារ ។

(ង) បំពេញមុខងារដទៃទៀត ដូចដែលអាចកំណត់ដោយសន្និសីទនៃភាគី ។

២. នៅក្នុងកិច្ចប្រជុំសាមញ្ញដំបូង សន្និសីទនៃភាគីត្រូវតែងតាំងលេខាធិការដ្ឋានបណ្តោះអាសន្នពីចំណោមអង្គការអន្តរជាតិមានសមត្ថភាព ដែលបានផ្តល់នូវចេតនាបំពេញមុខងារលេខាធិការដ្ឋាននៅក្រោមអនុសញ្ញានេះ ។

## មាត្រាទី ២៥

## ការផ្តល់យោបល់បច្ចេកវិទ្យា បច្ចេកទេស និងវិទ្យាសាស្ត្រ

១. អនុគណៈកម្មាធិការផ្តល់យោបល់បច្ចេកវិទ្យា បច្ចេកទេស និងវិទ្យាសាស្ត្រ ត្រូវបង្កើតឡើងដើម្បីផ្តល់សន្និសីទនៃភាគី និងក្រុមការងារដទៃទៀតនូវយោបល់ទាន់ពេលវេលាទាក់ទងនឹងការអនុវត្តន៍នៃអនុសញ្ញានេះ ។ អនុគណៈកម្មាធិការនេះត្រូវបើកចំហអោយមានការចូលរួមពីគ្រប់ភាគីនិងមានពហុជំនាញ ។ អនុគណៈកម្មាធិការត្រូវមានអ្នកតំណាងរដ្ឋាភិបាលមានសមត្ថកិច្ចលើជំនាញពាក់ព័ន្ធ ។ ក្រុមការងារ ត្រូវរាយការណ៍ជាទៀងទាត់ជូនសន្និសីទនៃភាគីលើគ្រប់ទិដ្ឋភាពនៃការងាររបស់ខ្លួន ។

២. នៅក្រោមដែនសមត្ថកិច្ច និងស្របជាមួយគោលការណ៍នៃការនាំចេញដោយសន្និសីទនៃភាគី ហើយដោយមានសេចក្តីស្នើ អនុគណៈកម្មាធិការនេះត្រូវ :

(ក) ផ្តល់ការវាយតំលៃបច្ចេកទេស និងវិទ្យាសាស្ត្រពីស្ថានភាពនៃជីវៈចំរុះ ។

(ខ) រៀបចំការវាយតំលៃបច្ចេកទេស និងវិទ្យាសាស្ត្រនៃផលប៉ះពាល់របស់វិធានការដែលបានអនុវត្តឡើង យោងតាម "ខ" នៃ អនុសញ្ញានេះ ។

(គ) ធ្វើអត្តសញ្ញាណកម្មបច្ចេកវិទ្យាបំផុតទាន់សម័យមានប្រសិទ្ធភាព និងមានលក្ខណៈច្នៃប្រឌិត និងចំណេះដឹងជាក់ស្តែង ទាក់ទង នឹងការអភិរក្សនិងការប្រើប្រាស់ដោយចីរភាពនៃជីវៈចំរុះ និងការផ្តល់យោបល់លើមធ្យោបាយលើក ស្ទួយការអភិវឌ្ឍន៍ ឬផ្ទេរ បច្ចេកវិទ្យានោះ ។

(ឃ) ផ្តល់យោបល់លើកម្មវិធីវិទ្យាសាស្ត្រ និងសហប្រតិបត្តិការ អន្តរជាតិខាងការស្រាវជ្រាវ និងការអភិវឌ្ឍន៍ទាក់ទងនឹងការ អភិរក្ស និងការប្រើប្រាស់ដោយចីរភាពនៃជីវៈចំរុះ ។

(ង) ឆ្លើយតបទៅនឹងសំនួរខាងវិធីសាស្ត្រ បច្ចេកវិទ្យា បច្ចេកទេស និងវិទ្យាសាស្ត្រដែលសន្និសីទនៃភាគី និងគណៈកម្មាធិការរបស់ ខ្លួនអាចចោទសួរ ។

៣. មុខងារ ការងារបច្ចេកទេសត្រូវដែលផ្តល់ជូនអង្គការ និងប្រតិបត្តិការរបស់គណៈកម្មាធិការនេះអាចយកមកពិភាក្សាអោយបានក្បោះក្បាយបន្ថែមទៀតដោយសន្និសីទនៃភាគីទុកពិចារណា ។

## មាត្រាទី ២៦

## របាយការណ៍

នៅរាល់ពេលវេលាអន្តរកាលមួយ កំណត់ដោយសន្និសីទនៃភាគីចុះកិច្ចសន្យានីមួយៗត្រូវដាក់ជូនសន្និសីទនៃភាគីនូវរបាយការណ៍ស្តីពីវិធានការដែលបានចាត់សំរាប់អនុវត្តនៃ "ខ" របស់អនុសញ្ញានេះ និងប្រសិទ្ធភាព ក្នុងការឆ្លើយតបទៅនឹងគោលបំណងនៃអនុសញ្ញានេះ ។

## មាត្រាទី ២៧

## ការរៀបចំបញ្ចប់ជំលោះ

១. ក្នុងករណីមានជំលោះរវាងភាគីចុះកិច្ចសន្យាពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍នៃអនុសញ្ញានេះ ភាគីចុះកិច្ចសន្យាត្រូវស្វែងរកដំណោះស្រាយតាមរយៈការចរចា ។

២. ប្រសិនបើភាគីពាក់ព័ន្ធ មិនអាចឈានដល់កិច្ចព្រមព្រៀងតាមរយៈការចរចា ភាគីទាំងនោះអាចរួមគ្នារកភាគីទី៣ ដើម្បីធ្វើអាជ្ញាកណ្តាលសំរបសំរួលរកដំណោះស្រាយ ។

៣. នៅពេលផ្តល់សច្ចាប័ន ទទួលយល់ព្រម ការឯកភាព ឬការចូលទៅនឹងអនុសញ្ញានេះ ឬនៅពេលណាមួយបន្ទាប់ពីការផ្តល់សច្ចាប័ននេះ រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតាមតំបន់ អាចប្រកាសជាលាយល័ក្ខអក្សរដល់រូបវន្តបុគ្គលដែលអាចជឿជាក់បានសំរាប់ជំលោះ ដែលមិនទាន់បានដោះស្រាយរួច យោងតាមកថាខ័ណ្ឌ១ ឬកថាខ័ណ្ឌ២ខាងលើមធ្យោបាយ១ ឬ២ អាចទទួលយកខានមិនបានសំរាប់បញ្ចប់ជំលោះដូចខាងក្រោម :

(ក) ការដោះស្រាយជំលោះយោងតាមនីតិវិធីដែលចែងក្នុងផ្នែកទី១នៃឧបសម្ព័ន្ធ២ ។

(ខ) ការបញ្ជូនជំលោះទៅតុលាការយុត្តិធម៌អន្តរជាតិ

៤. ប្រសិនបើគ្មានដំណោះស្រាយទៅនឹងជំលោះខាងលើ យោងតាមកថាខ័ណ្ឌខាងលើទទួលយកនីតិវិធីដដែល ឬដទៃទៀតត្រូវបញ្ជូន ជំលោះដើម្បីផ្សះផ្សាយោងតាមផ្នែកទី២ ឧបសម្ព័ន្ធ២ប្រសិនភាគីមិនឯកភាព ។

៥."ខ" នៃមាត្រានេះត្រូវអនុវត្តអោយស្របនឹងពិធីសារមានាលើកលែងតែពិធីសារពាក់ព័ន្ធ ។

## មាត្រាទី ២៨

## ការអនុម័តនៃពិធីសារ

១. ភាគីចុះកិច្ចសន្យា ត្រូវធ្វើសហប្រតិបត្តិការក្នុងការរៀបចំ និងអនុម័តនៃពិធីសារទាក់ទងនឹងអនុសញ្ញានេះ ។

២. ត្រូវអនុម័តពិធីសារនៅក្នុងកិច្ចប្រជុំនៃសន្និសីទនៃភាគី ។

៣. លេខាធិការដ្ឋាន ត្រូវបញ្ជូនអត្ថបទនៃសំណើពិធីសារទៅភាគីចុះកិច្ចសន្យាយ៉ាងហោចណាស់៦ខែ មុនកិច្ចប្រជុំចាប់ផ្តើម ។

## មាត្រាទី ២៩

## វិសោធនកម្មនៃអនុសញ្ញា ឬពិធីសារ

១. វិសោធនកម្មនៃអនុសញ្ញានេះ អាចស្នើដោយភាគីចុះកិច្ចសន្យាណាមួយ ។ វិសោធនកម្មនៃពិធីសារអាចស្នើដោយភាគីណាមួយដែលជាសមាជិកនៃពិធីសារនេះ ។

២. វិសោធនកម្មនៃអនុសញ្ញានេះ ត្រូវអនុម័តដោយកិច្ចប្រជុំរបស់សន្និសីទនៃភាគី ។ វិសោធនកម្មនៃពិធីសារត្រូវអនុម័តដោយកិច្ចប្រជុំរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារដោយលើកឡើងជាសំនួរ ។ អត្ថបទនៃសំណើវិសោធនកម្មទៅនឹងអនុសញ្ញានេះ ឬពិធីសារណាមួយលើកលែងតែអាចត្រូវបានផ្តល់នៅក្នុងពិធីសារនោះ លេខាធិការដ្ឋានត្រូវបញ្ជូនដល់ភាគីនានាជាមុនយ៉ាងហោចណាស់៦ខែ មុនកិច្ចប្រជុំដែលរៀបចំឡើងសំរាប់ការអនុម័តនោះ ។ លេខាធិការដ្ឋានត្រូវបញ្ជូនសំណើវិសោធនកម្មដល់ហត្ថលេខីនៃអនុសញ្ញានេះដើម្បីជ្រាបជាព័ត៌មាន ។

៣. ភាគីចុះកិច្ចសន្យា ត្រូវខិតខំអស់ពីសមត្ថភាពដើម្បីឈានដល់កិច្ចព្រមព្រៀងលើសំណើវិសោធនកម្មនៃអនុសញ្ញានេះ ។ ពិធីសារណាមួយ តាមរយៈការឯកភាពគ្នា ប្រសិនបើកិច្ចខិតខំទាំងនោះដើម្បីឈានដល់ការព្រមព្រៀងត្រូវបរាជ័យ វិសោធនកម្មនឹងត្រូវអនុម័តចុងក្រោយតាមរយៈការបោះឆ្នោតយកសំលេង ²/₃ នៃភាគី ដោយលើកជាសំនួរ និងបោះឆ្នោតនៅក្នុងកិច្ចប្រជុំហើយត្រូវបញ្ជូនដោយអ្នកទទួលបញ្ញើទៅកាន់ភាគីសំរាប់ការផ្តល់សច្ចាប័ន ការទទួលយក ឬការឯកភាព ។

៤. ការផ្តល់សច្ចាប័ន ការទទួលយក ឬការឯកភាពនៃវិសោធនកម្មត្រូវជូនដំណឹងដល់អ្នកទទួលបញ្ញើ ជាលាយលក្ខណ៍អក្សរ ។ វិសោធនកម្មដែលបានអនុម័តស្របទៅនឹងកថាខ័ណ្ឌទី ៣ខាងលើ ត្រូវចូលជាធរមានក្នុងចំណោមភាគីដែលបានឯកភាព ៩០ថ្ងៃ បន្ទាប់ពីការតំកល់ទុកនៃឧបករណ៍ផ្តល់សច្ចាប័នទទួលយក ឬឯកភាពដោយសំលេង ²/₃ នៃភាគចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ឬពិធីសារពាក់ព័ន្ធ លើកលែងតែផ្តល់ដោយពិធីសារនោះ ។ បន្ទាប់មកវិសោធនកម្មត្រូវចូលជាធរមានសំរាប់ភាគីដទៃទៀត៩០ថ្ងៃ បន្ទាប់ពីភាគីបានតំកល់ទុកឧបករណ៍ផ្តល់សច្ចាប័នរបស់ខ្លួន ការទទួលយក ឬឯកភាពលើវិសោធនកម្មនោះ ។

៥.សំរាប់គោលបំណងនៃមាត្រានេះ " ភាគីត្រូវវត្តមាន និងធ្វើការបោះឆ្នោត " មានន័យថាភាគីត្រូវវត្តមាន និងធ្វើការបោះឆ្នោតប្រឆាំង ឬទទួលយកវិសោធនកម្មនោះ ។

## មាត្រាទី ៣០

## ការអនុម័ត និងវិសោធនកម្មនៃឧបសម្ព័ន្ធនានា

១. ឧបសម្ព័ន្ធទៅនឹងអនុសញ្ញានេះ ឬពិធីសារណាមួយត្រូវបង្កើតជាផ្នែកដែលអាចបញ្ចូលនៃអនុសញ្ញា ឬពិធីសារហើយក្នុងករណីនេះ ប្រសិនបើមិនបានផ្តល់ការបកស្រាយទេ សេចក្តីយោងទៅនឹងអនុសញ្ញា ឬពិធីសារនោះត្រូវបង្កើតនៅពេលជាមួយគ្នានឹងសេចក្តីយោង និងឧបសម្ព័ន្ធនានា ។ ឧបសម្ព័ន្ធបែបនោះ ត្រូវដាក់កំហិតមិនមានការទាក់ទងដល់បញ្ហារដ្ឋបាល បច្ចេកទេស វិទ្យាសាស្ត្រ និងបែបបទឡើយ ។

២. លើកលែងតែបានផ្តល់នៅក្នុងពិធីសារលើឧបសម្ព័ន្ធនោះ បែបបទខាងក្រោមត្រូវអនុវត្តលើសំណើការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធបន្ថែមទៅនឹងអនុសញ្ញានេះ ឬឧបសម្ព័ន្ធទៅនឹងពិធីសារ :

(ក) ឧបសម្ព័ន្ធទៅនឹងអនុសញ្ញា ឬពិធីសារត្រូវតែស្នើឡើង និងអនុម័តអនុលោមទៅតាមបែបបទដែលបានចែងនៅក្នុង មាត្រាទី ២៩ ។

(ខ) ភាគីណាមួយដែលមិនអាចឯកភាព ទៅលើឧបសម្ព័ន្ធបន្ថែមណាមួយទៅនឹងអនុសញ្ញានេះ ឬពិធីសារត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកទទួលបញ្ញើក្នុងរយៈពេល ១ឆ្នាំចាប់ពីថ្ងៃជូនដំណឹងដោយអ្នកទទួលបញ្ញើអំពីការអនុម័តនោះ ។ អ្នកទទួលបញ្ញើត្រូវជូនដំណឹងដល់បណ្តាភាគីដោយមិនពន្យាពេលអំពីព័ត៌មានទទួលបាននោះ ។ ភាគីណាមួយអាចដកការជំទាស់ដែលប្រកាសពីពេលមុន មកនៅពេលណាក៏បានហើយឧបសម្ព័ន្ធត្រូវចូលជាធរមានចាប់ពេលនោះតទៅសំរាប់ភាគីនោះយោងទៅតាមអនុកថាខ័ណ្ឌ (គ) ខាងក្រោម :

(គ) នៅពេលផុតកំណត់រយៈពេល ១ឆ្នាំនៃការជូនដំណឹងអំពីការអនុម័តដោយអ្នកទទួលបញ្ញើឧបសម្ព័ន្ធ ត្រូវចូលជាធរមានសំរាប់គ្រប់ភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ឬពិធីសារពាក់ព័ន្ធដែលមិនទាន់បានធ្វើសេចក្តីជូនដំណឹង យោងតាមនៃអនុកថាខ័ណ្ឌ (ខ) ខាងលើ ។

៣. សំណើការអនុម័ត និងការចូលជាធរមាននៃវិសោធនកម្ម លើឧបសម្ព័ន្ធទៅនឹងអនុសញ្ញានេះ ឬពិធីសារណាមួយត្រូវអនុលោមទៅតាមបែបបទដូចគ្នានឹងសំណើការអនុម័ត និងការចូលជាធរមាននៃឧបសម្ព័ន្ធទៅនឹងអនុសញ្ញា ឬពិធីសារ ។

៤. ប្រសិនបើឧបសម្ព័ន្ធបន្ថែម ឬវិសោធនកម្មទៅនឹងឧបសម្ព័ន្ធណាមួយមានទាក់ទងនឹងវិសោធនកម្មនៃអនុសញ្ញានេះ ឬពិធីសារ ឧបសម្ព័ន្ធបន្ថែម ឬវិសោធនកម្មមិនត្រូវចូលជាធរមានរហូតដល់ពេលណាមួយនោះ ដែលវិសោធនកម្មទៅនឹងអនុសញ្ញា ឬពិធីសារពាក់ព័ន្ធចូលជាធរមាន ។

## មាត្រាទី ៣១

## សិទ្ធិក្នុងការបោះឆ្នោត

១. លើកលែងតែបានចែងនៅក្នុងកថាខ័ណ្ឌទី២ខាងក្រោមភាគីចុះកិច្ចសន្យានីមួយៗត្រូវមានសិទ្ធិបោះឆ្នោតមួយ ។

២.អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ទាក់ទងនឹងបញ្ហានៅក្រោមដែនសមត្ថកិច្ចពួកគេ ត្រូវប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោត ដែលមានសំលេងឆ្នោតស្មើនឹងចំនួនរដ្ឋជាសមាជិកបានចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ឬពិធីសារពាក់ព័ន្ធ ។ អង្គការនោះមិនត្រូវប្រើប្រាស់សិទ្ធិបោះឆ្នោតរបស់គេ ប្រសិនរដ្ឋជាសមាជិកប្រើប្រាស់ហើយជួយមកវិញ ។

## មាត្រាទី ៣២

## ទំនាក់ទំនងរវាងអនុសញ្ញានេះ និងពិធីសាររបស់វា

១. រដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ មិនអាចក្លាយជាភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ ប្រសិនបើរដ្ឋ ឬអង្គការនោះជាភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ឬក្លាយជាភាគីចុះកិច្ចសន្យានៅពេលជាមួយគ្នា ។

២. សេចក្តីសំរេចនៅក្រោមពិធីសារ ត្រូវតែទទួលដោយភាគីចុះកិច្ចសន្យាទៅនឹងពិធីសារពាក់ព័ន្ធ ។ ភាគីចុះកិច្ចសន្យាណាមួយមិនទាន់បានផ្តល់សច្ចាប័ន ទទួលយក ឬឯកភាពលើពិធីសារ អាចចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំណាមួយរបស់ភាគីចុះកិច្ចសន្យាទៅនឹងពិធីសារ ។

## មាត្រាទី ៣៣

## ការចុះហត្ថលេខា

អនុសញ្ញានេះត្រូវបើកចំហអោយចុះហត្ថលេខានៅទីក្រុង រីយ៉ូដឺហ្សាណេរ៉ូ ( Rio De Janeiro) ដល់គ្រប់រដ្ឋ និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ចាប់ពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩២ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩២ និងនៅទីចាត់ការដ្ឋានរបស់អង្គការសហប្រជាជាតិក្នុងបុរីញូវយ៉ក ( New York) ពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៩២ ដល់ពីថ្ងៃទី ៤ ខែមិថុនា ឆ្នាំ១៩៩៣ ។

## មាត្រា ៣៤

## ការផ្តល់សច្ចាប័ន ការព្រមទទួល និងការយល់ព្រម

១. អនុសញ្ញានេះ និងពិធីសារត្រូវតែធ្វើការផ្តល់សច្ចាប័ន ការព្រមទទួល ឬការយល់ព្រមពីបណ្តារដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ។ ឧបករណ៍នៃការផ្តល់សច្ចាប័ន ការព្រមទទួល និងការយល់ព្រមត្រូវតំកល់ទុកនៅជាមួយអ្នកទទួលបញ្ញើ ។

២. ដោយយោងទៅតាមកថាខណ្ឌ១ខាងលើ ប្រសិនបើអាចកើតមានឡើង អង្គការណាមួយអាចក្លាយជាភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ឬពិធីសារនានាដោយគ្មានសមាជិករដ្ឋណាមួយរបស់ខ្លួនក្លាយជាភាគីចុះកិច្ចសន្យា ត្រូវគោរពរាល់កាតព្វកិច្ចនៅក្រោមអនុសញ្ញានេះ ឬពិធីសារ ។ ក្នុងករណីនៃអង្គការបែបនោះ សមាជិកមួយ ឬច្រើននៃរដ្ឋជាសមាជិកជាភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ឬពិធីសារ ពាក់ព័ន្ធអង្គការ និងរដ្ឋជាសមាជិកត្រូវធ្វើសេចក្តីសំរេចលើការទទួលខុសត្រូវរបស់គេរៀងៗខ្លួន សំរាប់ការបំពេញនៃកាតព្វកិច្ចនៅក្រោមអនុសញ្ញានេះ ឬពិធីសារ ។ នៅក្នុងករណីបែបនេះ អង្គការ និងរដ្ឋជាសមាជិកមិនត្រូវប្រើប្រាស់សិទ្ធិរបស់ខ្លួននៅក្រោមអនុសញ្ញា ឬពិធីសារពាក់ព័ន្ធពេលតែមួយឡើយ ។

៣. នៅក្នុងឧបករណ៍នៃការផ្តល់សច្ចាប័ន ការព្រមទទួល និងការយល់ព្រមយោងតាមកថាខណ្ឌទី១ខាងលើ អង្គការត្រូវប្រកាសនូវទំហំនៃដែនសមត្ថកិច្ចទាក់ទងនឹងបញ្ហាគ្រប់គ្រងដោយអនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនោះត្រូវជូនពត៌មានដល់អ្នកទទួលយកបញ្ញើពីការកែតម្រូវជាធាតុក្នុងវិសាលភាពនៃដែនសមត្ថកិច្ចខ្លួន ។

## មាត្រា ៣៥

## ការចូលជាសមាជិក

១. អនុសញ្ញានេះ និងពិធីសារត្រូវបើកចំហអោយចូលជាសមាជិកដល់រដ្ឋនានា និងអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ចាប់ពីថ្ងៃដែលអនុសញ្ញា ឬពិធីសារពាក់ព័ន្ធត្រូវបានបញ្ចប់អោយចុះហត្ថលេខា ។ ឧបករណ៍នៃការចូលជាសមាជិក ត្រូវតំកល់ទុកជាមួយអ្នកទទួលបញ្ញើ ។

២. នៅក្នុងឧបករណ៍នៃការចូលជាសមាជិក យោងទៅតាមកថាខណ្ឌទី១ខាងលើ អង្គការត្រូវប្រកាសវិសាលភាពនៃដែនសមត្ថកិច្ចរបស់ខ្លួនទាក់ទងនឹងបញ្ហាគ្រប់គ្រងដោយអនុសញ្ញា ឬពិធីសារពាក់ព័ន្ធ ។ អង្គការទាំងនេះត្រូវជូនដំណឹងដល់អ្នកទទួលបញ្ញើផងដែរនូវការកែតំរូវនៅក្នុងវិសាលភាពនៃដែនសមត្ថកិច្ចរបស់ខ្លួន ។

៣. ខ នៃមាត្រាទី៣៤ កថាខណ្ឌទី ២ ត្រូវអនុវត្តលើអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលចូលជាសមាជិកនៃអនុសញ្ញានេះ ឬពិធីសារ ។

## មាត្រា ៣៦

## ការចូលជាធរមាន

១. អនុសញ្ញានេះត្រូវចូលជាធរមាន ៩០ថ្ងៃ ក្រោយពីថ្ងៃបន្ទាប់ពីថ្ងៃតំកល់ទុកនូវឧបករណ៍ទី៣០នៃការផ្តល់សច្ចាប័នការព្រមទទួល ការយល់ព្រម ឬការចូលជាសមាជិក ។

២. ពិធីសារណាមួយត្រូវចូលជាធរមាន៩០ថ្ងៃបន្ទាប់ពីថ្ងៃតំកល់ទុកចំនួនឧបករណ៍នៃការផ្តល់សច្ចាប័ន ការព្រមទទួល ការយល់ព្រម ឬការចូលជាសមាជិក ដែលបានបញ្ជាក់លំអិតនៅក្នុងពិធីសារនោះ ។

៣. ចំពោះភាគីចុះកិច្ចសន្យានីមួយៗ ដែលបានផ្តល់សច្ចាប័នព្រមទទួលយក ឬយល់ព្រមលើអនុសញ្ញានេះ ឬចូលជាសមាជិកនៃអនុសញ្ញារួចមក បន្ទាប់ពីតំកល់ឧបករណ៍ទី៣០នៃការផ្តល់សច្ចាប័នការព្រមទទួល ការយល់ព្រម ឬការចូលជាសមាជិកអនុសញ្ញានោះ ត្រូវជាធរមាន៩០ថ្ងៃ បន្ទាប់ពីថ្ងៃតំកល់ទុកនៃឧបករណ៍ផ្តល់សច្ចាប័ន ការព្រមទទួល ការយល់ព្រម ឬការចូលជាសមាជិកដោយភាគីចុះកិច្ចសន្យា ។

៤. លើកលែងតែបានចែងនៅក្នុងពិធីសារនោះ ពិធីសារណាមួយត្រូវចូលជាធរមានដល់ភាគីចុះកិច្ចសន្យាដែលបានផ្តល់សច្ចាប័នព្រមទទួល ឬយល់ព្រមលើពិធីសារនោះ ឬចូលជាសមាជិកយោងតាមកថាខ័ណ្ឌទី២ខាងលើ បន្ទាប់ពីពិធីសារចូលជាធរមាននៅថ្ងៃទី៩០ក្រោយពីភាគីចុះកិច្ចសន្យាតំកល់ទុក ឧបករណ៍នៃការផ្តល់សច្ចាប័ន ការព្រមទទួល ការយល់ព្រម ឬចូលជាសមាជិករបស់ខ្លួន ឬនៅថ្ងៃដែលអនុសញ្ញានេះចូលជាធរមានសំរាប់ភាគីចុះកិច្ចសន្យានោះ ។

៥. សំរាប់គោលបំណងនៃកថាខ័ណ្ឌទី១ និងទី២ខាងលើឧបករណ៍ណាមួយ ដែលបានតំកល់ទុកដោយអង្គការសមាហរណកម្មសេដ្ឋកិច្ច តំបន់មិនត្រូវរាប់ជាឧបករណ៍បន្ថែមលើឧបករណ៍តំកល់ទុកដោយរដ្ឋជាសមាជិកនៃអង្គការនោះ ។

## មាត្រាទី ៣៧

## សេចក្តីបំរុងទុក

ពុំមានការបំរុងទុកណាមួយអាចរៀបចំធ្វើសំរាប់អនុសញ្ញានេះឡើយ ។

## មាត្រាទី ៣៨

## ការដកចេញពីសមាជិកភាព

១. នៅពេលណាក៏ដោយបន្ទាប់ពី២ឆ្នាំ ចាប់ពីថ្ងៃដែលអនុសញ្ញានេះបានចូលជាធរមានសំរាប់ភាគីចុះកិច្ចសន្យាណាមួយ ភាគីនោះអាចដកខ្លួនចេញពីអនុសញ្ញាដោយផ្តល់ការជូនដំណឹងជាលាយល័ក្ខអក្សរដល់អ្នកទទួលបញ្ញើ ។

២. ការដកសមាជិកភាពណាមួយ ត្រូវធ្វើឡើងនៅពេលផុតកំណត់រយៈពេល១ឆ្នាំ បន្ទាប់ពីថ្ងៃដែលអ្នកទទួលបញ្ញើបានទទួលការជូនដំណឹងនោះ ឬនៅថ្ងៃបន្ទាប់មកដូចដែលអាចបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងពីការដកសមាជិកភាពចេញ ។

៣. ភាគីចុះកិច្ចសន្យាណាដែលដកខ្លួនចេញពីអនុសញ្ញានេះត្រូវចាត់ទុកថាបានដកខ្លួនចេញពី ពិធីសារពាក់ព័ន្ធដែលភាគីបានចុះកិច្ចសន្យា ។

## មាត្រាទី ៣៩

## ការរៀបចំហិរញ្ញវត្ថុអន្តរកាល

ដូចដែលបានរៀបចំត្រឹមត្រូវ ផ្អែកតាមតំរូវការនៃមាត្រាទី២១ អង្គការមូលនិធិបរិស្ថានពិភពលោកនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ កម្មវិធីបរិស្ថានសហប្រជាជាតិ និងធនាគារអន្តរជាតិសំរាប់ការស្ថាបនាឡើង និងការអភិវឌ្ឍន៍ត្រូវជារចនាសម្ព័ន្ធស្ថាប័ន

យោងតាមមាត្រាទី២១ ដើម្បីបង្កើតបណ្តោះអាសន្ន សំរាប់រយៈពេលចន្លោះការចូលជាធរមាននៃអនុសញ្ញានេះ និងកិច្ចប្រជុំលើកទី១នៃសន្និសីទភាគី ឬរហូតដល់សន្និសីទភាគីធ្វើសេចក្តីសំរេចថាតើរចនាសម្ព័ន្ធស្ថាប័នណាមួយត្រូវបង្កើតឡើងផ្អែកតាមមាត្រាទី ២១ ។

## មាត្រាទី ៤០

## ការរៀបចំអន្តរកាលលេខាធិការដ្ឋាន

លេខាធិការដ្ឋានដែលផ្តល់ដោយ នាយកប្រតិបត្តិនៃកម្មវិធីបរិស្ថានសហប្រជាជាតិ គឺជាលេខាធិការដ្ឋានផ្អែកលើមាត្រាទី២៤ កថាខ័ណ្ឌទី២ មានមូលដ្ឋានបណ្តោះអាសន្នសំរាប់រយៈពេលចន្លោះពីការចូលជាធរមាននៃអនុសញ្ញានេះ និងកិច្ចប្រជុំលើកទី១ នៃសន្និសីទភាគី ។

## មាត្រាទី ៤១

## អ្នកទទួលបញ្ញើ

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវទទួលការងារជាអ្នកទទួលបញ្ញើ (Depositary) នៃអនុសញ្ញានេះ និងពិធីសារពាក់ព័ន្ធ ។

## មាត្រាទី ៤២

## ច្បាប់ដើមនៃអនុសញ្ញា

ច្បាប់ដើមនៃអនុសញ្ញានេះ ជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញមានតំលៃស្មើៗគ្នា ត្រូវតំកល់ទុកជាមួយអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

ជាសាក្សីដោយមានហត្ថលេខាភ្ជាប់ជាមួយ ត្រូវបានផ្តល់អំណាចដើម្បីធ្វើការងារទៅជាធរមាន ។ បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅរីយ៉ូ ដឺ ជេណេរ៉ូ (Rio de Janeiro) នៅថ្ងៃទី៥ ខែ មិថុនា ឆ្នាំ១៩៩២

**ឧបសម្ព័ន្ធ I :**

-អត្តសញ្ញាណកម្ម និងការតាមឃ្លាំមើល

១. ប្រព័ន្ធអេកូឡូស៊ី និងដែនជំរក : មានជីវៈចំរុះខ្ពស់មានចំនួនប្រភេទក្នុងស្រុកច្រើន ឬប្រភេទទទួលរងការគំរាមកំហែង ឬមានលក្ខណៈព្រៃពុំទាន់មានការបំផ្លិចបំផ្លាញ ត្រូវការឲ្យមានប្រភេទពនេចរមានសារៈសំខាន់ខាងសង្គម សេដ្ឋកិច្ច វប្បធម៌ ឬវិទ្យាសាស្ត្រ ឬដែលមានលក្ខណៈតំណាងលេចធ្លោជាមួយដំណើរវិវត្តន៍ ឬជាមួយជីវសាស្ត្រដទៃទៀត ។

២. ប្រភេទ និងសហគមន៍ : គឺទទួលរងការគំរាមកំហែងមានលក្ខណៈព្រៃ ឬប្រភេទបង្កាត់បង្កើត ឬផ្សាំមានសារៈសំខាន់សំរាប់ឱសថ កសិកម្ម ឬតំលៃសេដ្ឋកិច្ចដទៃទៀត ឬសារៈសំខាន់ខាងសង្គម វិទ្យាសាស្ត្រ ឬវប្បធម៌ ឬសារៈសំខាន់សំរាប់ការស្រាវជ្រាវលើការអភិរក្ស និងការប្រើប្រាស់ដោយចីរភាពនៃជីវៈចំរុះ ដូចជាប្រភេទជាទស្សន៍បង្ហាញ ។

៣. ចារិកជាប់ឬសារៈសំខាន់នៃសំភារៈសេនេទិច ដែលសង្គមវិទ្យាសាស្ត្រ និងសេដ្ឋកិច្ច ។

## ឧបសម្ព័ន្ធ II : ផ្នែកទី ១

- ការដោះស្រាយជំលោះ

### មាត្រាទី ១

ភាគីដើមចោទ ត្រូវជូនដំណឹងដល់លេខាធិការដ្ឋានថា ភាគីបានពាក់ព័ន្ធនឹងជំលោះ ដើម្បីធ្វើការដោះស្រាយជំលោះអនុលោមតាម មាត្រាទី២៧ ។ ការជូនដំណឹងត្រូវបញ្ជាក់ពីប្រធានបទនៃបញ្ហាសំរាប់ដោះស្រាយ និងបញ្ចូលជាពិសេសមាត្រានៃអនុសញ្ញា ឬពិធីសារ នូវការបកស្រាយ ឬការអនុវត្តន៍ដែលជាបញ្ហា ។ ប្រសិនបើភាគីនោះមិនឯកភាពលើប្រធានបទបញ្ហានៃជំលោះ មុនពេលប្រធាននៃ អង្គចៅក្រម ត្រូវបង្កើតឡើងអង្គចៅក្រមកាត់ក្តីត្រូវកំណត់នូវប្រធានបទបញ្ហានោះ ។ ដូចនេះលេខាធិការដ្ឋាន ត្រូវបញ្ជូនព័ត៌មានដែល បានទទួលទៅគ្រប់ភាគីចុះកិច្ចសន្យាទៅនឹងអនុសញ្ញានេះ ឬពិធីសារពាក់ព័ន្ធ ។

### មាត្រាទី ២

១. ក្នុងជំលោះរវាង ២ភាគី អង្គចៅក្រមកាត់ក្តីត្រូវបង្កើតដោយសមាជិក៣នាក់ ។ ភាគីនីមួយៗពាក់ព័ន្ធនឹងជំលោះ ត្រូវតែងតាំងចៅក្រមម្នាក់ ហើយចៅក្រមពីរនាក់ដែលតែងតាំងនោះត្រូវរៀបចំបង្កើតចៅក្រមទី៣ ដោយមានការឯកភាពរួមដែលនឹងជាប្រធាន នៃអង្គចៅក្រមកាត់ក្តី ។ ប្រធានអង្គចៅក្រម មិនត្រូវជាសញ្ជាតិនៃភាគីពាក់ព័ន្ធនឹងជំលោះឡើយ ឬមិនត្រូវមានកន្លែងស្នាក់នៅធម្មតា ក្នុងទឹកដីនៃភាគីមួយក្នុងចំណោមភាគីទាំងនោះឡើយ ឬមិនធ្លាប់បានបំរើការអោយភាគីទាំងពីរ ឬមិនធ្លាប់បានដោះស្រាយក្តីក្តាំក្នុង សមត្ថកិច្ចដទៃទៀតឡើយ ។

២. ក្នុងជំលោះរវាងភាគី២ ឬច្រើនភាគី ស្ថិតក្នុងផលប្រយោជន៍ដូចគ្នាត្រូវតែងតាំងចៅក្រមរួមមួយតាមរយៈការឯកភាពគ្នា ។

៣. ប៉ុស្តិ៍ (កន្លែង) ទំនេរណាមួយត្រូវបំពេញក្នុងបច្ចោបាយដែលបានចែងសំរាប់ការតែងតាំងលើកដំបូង ។

### មាត្រាទី ៣

១. ប្រសិនបើប្រធាននៃអង្គចៅក្រមកាត់ក្តី មិនត្រូវបានតែងតាំងក្នុងរយៈពេល២ខែនៃការតែងតាំងចៅក្រមទី២ អគ្គលេខាធិការ នៃអង្គការសហប្រជាជាតិ ត្រូវតែងតាំងប្រធានអង្គចៅក្រមក្នុងរយៈពេល២ខែ បន្ថែមដោយមានសំណើរពីភាគី ។

២. ប្រសិនបើភាគីមួយ ក្នុងចំណោមភាគីមានជំលោះមិនទាន់តែងតាំងចៅក្រមក្នុងរយៈពេល ២ខែ បន្ទាប់ពីការទទួលសំណើរ ភាគីដទៃទៀតអាចជូនដំណឹងដល់ អគ្គលេខាធិការនៃសហប្រជាជាតិដែលត្រូវធ្វើការតែងតាំងក្នុងកំឡុងពេល ២ខែបន្ថែម ។

### មាត្រាទី ៤

ចៅក្រមកាត់ក្តី ត្រូវអនុវត្តសេចក្តីសំរេចរបស់ខ្លួនអនុលោមតាមបទប្បញ្ញត្តិ នៃអនុសញ្ញានេះពិធីសារពាក់ព័ន្ធ និងច្បាប់អន្តរជាតិ ។

### មាត្រាទី ៥

ប្រសិនបើភាគីមានជំលោះ មិនឯកភាពនោះទេ អង្គចៅក្រមកាត់ក្តីត្រូវកំណត់បែបបទនៃបទបញ្ជារបស់ខ្លួនផ្ទាល់ ។

### មាត្រាទី ៦

ដោយមានសំណើពីភាគីមួយក្នុងចំណោមភាគីមានជំលោះ អង្គចៅក្រមកាត់ក្ដីអាចស្នើវិធានការការពារចាំបាច់បណ្ដោះអាសន្ន ។

### មាត្រាទី ៧

ភាគីមានជំលោះ ត្រូវជួយសំរួលការងាររបស់អង្គចៅក្រមកាត់ក្ដី ហើយជាពិសេសដោយប្រើប្រាស់គ្រប់មធ្យោបាយដែលមានត្រូវ :

ក. ផ្ដល់អង្គចៅក្រមនូវរាល់ឯកសារពាក់ព័ន្ធ ព័ត៌មាន និងសំភារៈ ។

ខ. ជួយដល់អង្គចៅក្រមនៅពេលណាចាំបាច់ដើម្បីកោះអញ្ជើញសាក្សី ឬអ្នកជំនាញការ និងទទួលភស្តុតាងរបស់ខ្លួន ។

### មាត្រាទី ៨

ភាគី និងចៅក្រមស្ថិតនៅក្រោមកាតព្វកិច្ចដើម្បីការពារពត៌មានលក្ខណៈការណ៍ ដែលពួកខ្លួនទទួលដោយសំងាត់ក្នុងកំឡុងពេលបើកដំណើរការនៃអង្គចៅក្រម ។

### មាត្រាទី ៩

ប្រសិនបើអង្គចៅក្រមកាត់ក្ដីមិនបានកំណត់បានការចំណាយទេនោះ ដោយសារតែកាលៈទេសៈពិសេសណាមួយ ការចំណាយរបស់តុលាការត្រូវចេញដោយភាគីមានជំលោះស្មើៗគ្នា ។ តុលាការត្រូវរក្សាទុកនូវរាល់ឯកសារចំណាយហើយភ្ជាប់ចូលក្នុងរបាយការណ៍ចុងក្រោយរបស់ខ្លួនដែលនឹងផ្ញើទៅភាគី ។

### មាត្រាទី ១០

ភាគីចុះកិច្ចសន្យាណាមួយដែលមានផលប្រយោជន៍ទាក់ទងនឹងបញ្ហាជំលោះ ដែលអាចទទួលរងការប៉ះពាល់ដោយសេចក្ដីសំរេចក្នុងរឿងក្ដីអាចអន្តរាគមន៍ក្នុងដំណើរការរឿងក្ដីអោយស្របគ្នានឹងតុលាការ ។

### មាត្រាទី ១១

តុលាការអាចស្ដាប់ និងកំណត់បណ្ដឹងជំទាស់ដែលចេញពីបញ្ហានៃជំលោះ ។

### មាត្រាទី ១២

សេចក្ដីសំរេចទាំងលើបែបបទ ខ្លឹមសារនៃតុលាការជំនុំជំរះក្ដីត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតយកសំលេងភាគច្រើននៃសមាជិករបស់ខ្លួន ។

### មាត្រាទី ១៣

ប្រសិនបើភាគីណាមួយនៃបណ្ដាភាគីមានជំលោះ មិនបានបង្ហាញមុខមុនពេលតុលាការជំនុំជំរះក្ដី ឬបរាជ័យក្នុងការការពារក្ដី ភាគីដទៃទៀត អាចស្នើតុលាការអោយបន្តដំណើរការការពារក្ដី ។ អវត្តមាននៃភាគីណាមួយ ឬការបរាជ័យក្នុងការការពារក្ដី មិនត្រូវជា

ឧបសគ្គដល់ដំណើរការកាត់ក្តី ។ មុនពេលប្រកាសសេចក្តីសំរេចចុងក្រោយរបស់ខ្លួន តុលាការកាត់ក្តីត្រូវបញ្ជាក់នូវការពេញចិត្តដោយខ្លួនឯង ថារឿងក្តីត្រូវបានសំរេចយ៉ាងច្បាស់លាស់ និងតាមច្បាប់ ។

### មាត្រាទី ១៤

តុលាការត្រូវប្រកាសសេចក្តីសំរេចចុងក្រោយក្នុងរយៈពេល៥ខែនៃថ្ងៃដែលតុលាការត្រូវបានបង្កើតឡើងពេញលេញ ប្រសិនតុលាការ មិនយល់ឃើញថាចាំបាច់ក្នុងការពន្យាពេលសំរាប់រយៈពេលមិនលើសពី ៥ខែបន្ថែមទៀត ។

### មាត្រាទី ១៥

សេចក្តីសំរេចចុងក្រោយរបស់តុលាការត្រូវជាក់កំហិតទៅនឹងប្រធានបទជំលោះ និងត្រូវបញ្ជាក់ពីហេតុផលដែលតុលាការផ្អែកលើ ។ តុលាការត្រូវរក្សាឈ្មោះសមាជិកដែលបានចូលរួម និងកាលបរិច្ឆេទនៃសេចក្តីសំរេចចុងក្រោយ ។ សមាជិកណាមួយនៃតុលាការអាចភ្ជាប់នូវទស្សនៈមិនឯកភាពទៅនឹងសេចក្តីសំរេចចុងក្រោយ ។

### មាត្រាទី ១៦

រង្វាន់គឺជាកាតព្វកិច្ចរបស់ភាគីមានជំលោះ ។ ដោយគ្មានបណ្តឹងតវ៉ា ប្រសិនបើភាគីមានជំលោះមិនបានឯកភាពជាមុននឹងបែបបទតុលាការ ។

### មាត្រាទី ១៧

ជំលោះវែងឆ្ងាយដែលអាចកើតចេញពីចំណោមភាគីដែលមានជំលោះដូចជាការបកស្រាយ ឬគោលបំណងនៃការអនុវត្តន៍សេចក្តីសំរេចចុងក្រោយ អាចធ្វើដោយភាគីណាមួយសំរាប់ជាសេចក្តីសំរេចដល់តុលាការដែលបានប្រកាសសេចក្តីសំរេចនោះ ។

**ភាគ I : ការសម្រុះសម្រួល**

### មាត្រាទី ១

ស្នងការសំរុះសំរួលត្រូវបង្កើតឡើងដោយមានសំណើពី ភាគីមួយក្នុងចំណោមភាគីមានជំលោះ ។ ប្រសិនបើភាគីមិនបានឯកភាពទេនោះ ស្នងការត្រូវមានសមាជិក៥នាក់. ២នាក់តែងតាំងដោយភាគីនីមួយៗ និងប្រធានម្នាក់ត្រូវជ្រើសរើសរួមគ្នាដោយសមាជិក នោះ ។

### មាត្រាទី ២

ក្នុងជំលោះរវាងលើសពី ២ភាគី ភាគីដែលមានផលប្រយោជន៍រួមត្រូវតែងតាំងរួមគ្នាសមាជិកនៃស្នងការ ដោយមានក រ ឯកភាព ។ នៅពេលមានភាគី ២ ឬច្រើនមានផលប្រយោជន៍ផ្សេង ឬមិនឯកភាព ភាគីនោះត្រូវតែងតាំងសមាជិកខ្លួនដាច់ដោយឡែក ។

### មាត្រាទី ៣

ប្រសិនបើការតែងតាំងដោយភាគី មិនបានធ្វើឡើងក្នុងរយៈពេល២ខែនៃថ្ងៃ ស្នើដើម្បីបង្កើតស្នងការសម្រុះសម្រួលទេនោះ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវធ្វើការតែងតាំងនោះ ក្នុងរយៈពេល២ខែបន្ថែម ប្រសិនបើមានសំណើរពីភាគី ។

## មាត្រាទី ៤

ប្រសិនបើប្រធាននៃស្នងការសម្រុះសម្រួល មិនបានជ្រើសរើសក្នុងរយៈពេល២ខែនៃថ្ងៃសមាជិកចុងក្រោយរបស់ស្នងការ ក៏ពុំត្រូវបានតែងតាំងទេនោះ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិត្រូវតែងតាំងប្រធានក្នុងរយៈពេល២ខែបន្ថែម ប្រសិនបើមានសំណើពីភាគី ។

## មាត្រាទី ៥

ស្នងការសម្រុះសម្រួល ត្រូវរៀបចំសេចក្តីសំរេចតាមរយៈការបោះឆ្នោតនៃសមាជិករបស់ខ្លួន ។ ប្រសិនបើភាគីមានជំលោះមិនឯកភាពទេនោះ ស្នងការត្រូវកំណត់បែបបទខ្លួនផ្ទាល់ ។ ស្នងការត្រូវបញ្ចូលសំណើសំរាប់ដំណោះស្រាយនៃជំលោះដែលភាគីត្រូវពិចារណាលើក្នុងឆន្ទៈល្អ ។

## មាត្រាទី ៦

ការមិនឯកភាពទៅនឹងសមត្ថកិច្ចរបស់ស្នងការសម្រុះសម្រួលត្រូវសំរេចដោយស្នងការ ។

## ហត្ថលេខីនៃអនុសញ្ញាស្តីពីជីវៈចំរុះនៅក្នុងសន្និសីទនៃអង្គការសហប្រជាជាតិលើបរិស្ថាន និងការអភិវឌ្ឍន៍

( រីយ៉ូដឺ ហ្សានេរ៉ូ, ថ្ងៃទី ៣-១៤ ខែមិថុនា ឆ្នាំ១៩៩២ )

| | ភាគីហត្ថលេខី | កាលបរិច្ឆេទនៃការចុះហត្ថលេខា |
|---|---|---|
| 1. | ប្រទេស អង់ទីហ្គា និងបាប៊ូដា | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 2. | ប្រទេស អូស្ត្រាលី | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 3. | ប្រទេស បង់ក្លាដេស | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 4. | ប្រទេស បែលហ្ស៊ិក | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 5. | ប្រទេស ប្រេស៊ីល | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 6. | ប្រទេស ហ្វាំងឡង់ | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 7. | ប្រទេស ឥណ្ឌា | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 8. | ប្រទេស ឥណ្ឌូនេស៊ី | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 9. | ប្រទេស អ៊ីតាលី | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 10. | ប្រទេស លិចតេនស្តែន | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 11. | សាធារណរដ្ឋ ម៉ុលដូវ៉ា | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 12. | ប្រទេស ន័រវេ | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 13. | ប្រទេស ហូឡង់ | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 14. | ប្រទេស ប៉ាគីស្ថាន | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 15. | ប្រទេស ប៉ូឡូញ | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |
| 16. | ប្រទេស រូម៉ានី | ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ១៩៩២ |

ក្រសួងបរិស្ថាន

អនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះ

| | | |
|---|---|---|
| 17. | ប្រទេស បុសស្វាណា | ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ១៩៩២ |
| 18. | ប្រទេស ម៉ាដាកាស្កា | ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ១៩៩២ |
| 19. | ប្រទេស ស៊ុយអែត | ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ១៩៩២ |
| 20. | ប្រទេស ទូកែលូ | ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ១៩៩២ |
| 21. | ប្រទេស យូហ្គោស្លាវី | ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ១៩៩២ |
| 22. | ប្រទេស បារ៉ែន | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 23. | ប្រទេស អេក្វាដ័រ | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 24. | ប្រទេស អេហ្ស៊ីប | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 25. | ប្រទេស កាហ្សាក់ស្ថាន | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 26. | ប្រទេស កូវ៉ែត | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 27. | ប្រទេស លុចហ្សំប៊ឺក | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 28. | ប្រទេស ន័រវេ | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 29. | ប្រទេស ស៊ូដង់ | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 30. | ប្រទេស អ៊ុយរ៉ាហ្គាយ | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 31. | ប្រទេស វ៉ាណោទូ | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ១៩៩២ |
| 32. | ប្រទេស កូម៉ូរ | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 33. | ប្រទេស អេត្យូពី | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 34. | ប្រទេស រកាយលែន | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 35. | ប្រទេស ម៉ាឡាវី | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 36. | ប្រទេស ហារីតុស | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 37. | ប្រទេស រូម៉ង់ | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 38. | ប្រទេស រ្វ៉ាន់ដា | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 39. | ប្រទេស សាន់ម៉ារីណូ | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 40. | ប្រទេស ស៊ុយឆិលលេស | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 41. | ប្រទេស ស្រីលង្កា | ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩២ |
| 42. | ប្រទេស បែលឡារុស | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 43. | ប្រទេស ប៊ូតង់ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 44. | ប្រទេស ប៊ូរុណ្ឌី | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 45. | ប្រទេស កាណាដា | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 46. | ប្រទេស ចិន | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 47. | ប្រទេស កូប៉ូរ៉ុស | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |

| ក្រសួងបរិស្ថាន | | អនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះ |
| --- | --- | --- |
| 48. | ប្រទេស កុងហ្គោ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 49. | ប្រទេស ក្រូអាស៊ី | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 50. | សាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យ កូរ៉េ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 51. | ប្រទេស អ៊ីស្រាអែល | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 52. | ប្រទេស ចាមីការ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 53. | ប្រទេស ហ្សកដង់ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 54. | ប្រទេស កិនយ៉ា | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 55. | ប្រទេស ឡាតវៀរ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 56. | ប្រទេស លីសុថុ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 57. | ប្រទេស លីទុយអានី | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 58. | ប្រទេស ម៉ូណាកូ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 59. | ប្រទេស មីយ៉ាម៉ា | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 60. | ប្រទេស នីហ្សេ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 61. | ប្រទេស កាតា | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 62. | ប្រទេស ទ្រីនីដាត និងតូបាហ្គោ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 63. | ប្រទេស ទួគី | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 64. | ប្រទេស អ៊ុយក្រែន | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 65. | សហព័ន្ធអារ៉ាប់ អេមីរ៉ែត | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 66. | ប្រទេស ហ្សាអៀរ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 67. | ប្រទេស ហ្សាមបៀរ | ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ១៩៩២ |
| 68. | ប្រទេស អាហ្វាគីស្ថាន | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 69. | ប្រទេស អង់ហ្គោឡា | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 70. | ប្រទេស អាហ្សង់ទីន | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 71. | ប្រទេស អាស៊ែបៃហ្សង់ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 72. | ប្រទេស បាហាម៉ាស | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 73. | ប្រទេស បារបាដុស | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 74. | ប្រទេស ប៊ុលហ្គារី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 75. | ប្រទេស ប៊ួគីណៀរ ហ្វាសូ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 76. | ប្រទេស កាពីវែរ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 77. | ប្រទេស ឆាដ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 78. | ប្រទេស កូឡុំប៊ី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |

ក្រសួងបរិស្ថាន អនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះ

| | | |
|---|---|---|
| 79. | ប្រជុំកោះ ឃុក | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 80. | ប្រទេស គុបា | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 81. | ប្រទេស សាយព្រ៊ុស | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 82. | ប្រទេស ដាណើម៉ាក | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 83. | ប្រទេស អេក្វាឌ័រ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 84. | ប្រទេស ហ្គាបុង | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 85. | ប្រទេស ហ្គាបវៀរ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 86. | ប្រទេស អាល្លឺម៉ង់ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 87. | ប្រទេស ហ្គាណា | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 88. | ប្រទេស ក្រិច | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 89. | ប្រទេស ហ្គីនេ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 90. | ប្រទេស ហ្គីនេ-ប៊ីសសៅ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 91. | ប្រទេស លីបង់ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 92. | ប្រទេស លីបេរីយ៉ា | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 93. | ប្រទេស ម៉ាលេស៊ី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 94. | ប្រទេស ម៉ាល់ឌីវ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 95. | ប្រទេស ម៉ាល់តា | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 96. | ប្រជុំកោះ ម៉ាស្សាល | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 97. | ប្រទេស ម៉ូរីតានី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 98. | ប្រទេស មីក្រូនេស៊ី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 99. | ប្រទេស ម៉ុងហ្គោលី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 100. | ប្រទេស ម៉ូហ្សាំប៊ិក | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 101. | ប្រទេស ណាមីប៊ី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 102. | ប្រទេស នេប៉ាល់ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 103. | ប្រទេស ញូវហ្សេឡែន | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 104. | ប្រទេស ប៉ារ៉ាហ្គាយ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 105. | ប្រទេស ប៉េរូ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 106. | ប្រទេស ហ្វីលីពីន | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 107. | ប្រទេស សែនឃីត និងណេវី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 108. | ប្រទេស សាម័រ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 109. | ប្រទេស សៅតូម៉េ និងព្រីនស៊ីប | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |

ក្រសួងបរិស្ថាន អនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ

| | |
|---|---|
| 110. ប្រទេស ស្វែហ្ស៊ីលែន | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 111. ប្រទេស ស្វីស | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 112. ប្រទេស ថៃ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 113. ប្រទេស តូហ្គោ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 114. ប្រទេស អ៊ូហ្គង់ដា | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 115. ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 116. សហព័ន្ធសាធារណរដ្ឋ តង់ហ្សានី | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 117. ប្រទេស វេណេស៊ុយអេឡា | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 118. ប្រទេស យេម៉ែន | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 119. ប្រទេស ហ្ស៊ីមបាវេ | ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៩២ |
| 120. ប្រទេស អាល់ហ្សេរី | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 121. ប្រទេស អាមេនី | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 122. ប្រទេស អូទ្រីស | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 123. ប្រទេស បេឡារុស | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 124. ប្រទេស បេនីន | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 125. ប្រទេស បូលីវី | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 126. សាធារណរដ្ឋ អាហ្វ្រិកកណ្ដាល | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 127. ប្រទេស ឈីលី | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 128. ប្រទេស កូស្តារីកា | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 129. ប្រទេស ជីប៊ូទី | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 130. សាធារណរដ្ឋ ដូមីនិក | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 131. ប្រទេស អែល សាល់វ៉ាឌ័រ | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 132. សហគមន៍សេដ្ឋកិច្ច សហភាពអឺរ៉ុប | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 133. ប្រទេស បារាំង | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 134. ប្រទេស ហ្គាតេម៉ាឡា | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 135. ប្រទេស ហ្គីយ៉ាណា | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 136. ប្រទេស ហៃទី | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 137. ប្រទេស ហុងគ្រី | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 138. ប្រទេស ហុងឌូរ៉ាស់ | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 139. ប្រទេស អៀរឡង់ | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |
| 140. ប្រទេស ជប៉ុន | ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២ |

141. ប្រទេស ម៉ិកស៊ិក ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
142. ប្រទេស ម៉ារ៉ុក ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
143. ប្រទេស នីការ៉ាហ្គ័រ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
144. ប្រទេស នីហ្សេរីយ៉ា ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
145. ប្រទេស ន័រវែក ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
146. ប្រទេស ប៉ាពូ ញូហ្គីណេ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
147. ប្រទេស ព័រទុយហ្គាល់ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
148. សាធារណៈរដ្ឋ កូរ៉េ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
149. សហព័ន្ធ រុស្ស៊ី ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
150. ប្រទេស សេណេហ្គាល់ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
151. ប្រទេស ស្លូវេនៀ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
152. ប្រជុំកោះ សូឡូម៉ូន ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
153. ប្រទេស អេស្ប៉ាញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
154. ប្រទេស ស៊ុយអែត ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
155. ប្រទេស ទុយនេស៊ី ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ១៩៩២
156. ប្រទេស កាមេរូន ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ១៩៩២
157. ប្រទេស អ៊ីរ៉ង់ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ១៩៩២